# សេចក្តីសង្ខេបបំពេញបន្ថែមរបស់
# ក្រុមហ៊ុន BP Exploration & Production

ចុះថ្ងៃទី7 ខែកក្កដា ឆ្នាំ 2011។

នៅក្នុងជម្រើសនៃការទូទាត់សំណងដែលកំពុងគ្រប់គ្រងគោលការណ៍ច្បាប់ចុងក្រោយចុះថ្ងៃទី18 ខែកុម្ភះ ឆ្នាំ 2011 លក្ខខណ្ឌសមស្រប និងសិទ្ធិទទួលបាន និងវិធីសាស្ត្រក្នុងការទូទាត់សំណងចុងក្រោយ ("វិធីសាស្ត្រចុងក្រោយ") របស់ខ្លួន ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ ("GCCF") បានអញ្ជើញអោយមានការចេញជាមតិយោបល់ពីអ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍:

**"ស្ថាប័ន GCCF សូមស្វាគមន៍នូវគំនិតយោបល់ដែលកើតចេញពីអ្នកទាមទារសំណង និងដៃគូរចំណាប់អារម្មណ៍ផ្សេងទៀត ក្នុងនាមឆ្លោះទៅដល់ការទូទាត់សំណងចុងក្រោយ ការទូទាត់សំណងឆាប់រហ័ស និងការទូទាត់សំណងបណ្តោះអាសន្ន ។"** វិធីសាស្ត្រចុងក្រោយ 9 (សង្កត់ធ្ងន់ទៅលើប្រភពដើម)។ ក្រុមហ៊ុន BP Exploration & Production ("BP") បានផ្តល់នូវមតិយោបល់ខាងក្រោមដោយក្តីគោរពដើម្បីបង្ហាញពីបញ្ហានៃការព្រួយបារម្ភណ៍សំខាន់ៗជាច្រើនទៅលើគោលបំណងពាក្យបណ្តឹងទាមទារសំណងរបស់ស្ថាប័ន GCCF បានទាន់ពេលវេលា។

## <u>សេចក្តីផ្តើម</u>

នៅថ្ងៃទី 23 ខែសីហា ឆ្នាំ2010 ស្ថាប័ន GCCF បានសន្មតពីទំនួលខុសត្រូវក្នុងការវាយតម្លៃ និងដំណោះស្រាយទៅលើពាក្យបណ្តឹងទាមទារសំណងបុគ្គល និងអាជីវកម្ម

ដែលបានដាក់ប្តឹងជាមួយនឹងក្រុមហ៊ុនប្រេងប៊ីភី BP ដោយអនុលោមតាមច្បាប់កង្វក់នៃប្រេងឆ្នាំ 1990 ("OPA") ក៏ដូចជាពាក្យបណ្តឹងទាមទារសំណងសម្រាប់គ្រោះថ្នាក់រាងកាយ និងមរណៈភាព។ ស្ថាប័ន GCCF មានការពេញចិត្តក្រៃលែងទៅលើកាតព្វកិច្ចរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ដោយអនុលោមតាមច្បាប់ OPA ដើម្បីបង្កើតអោយមានដំណើរការទទួលយក និងវាយតម្លៃពាក្យបណ្តឹងទាមទារសំណង។ ដូច្នេះ ស្ថាប័ន GCCF បានធ្វើសកម្មភាពលើសពីតម្រូវការនិតិក្រមរបស់ច្បាប់ OPA យ៉ាងច្រើន ដោយរៀបចំរចនានូវកម្មវិធីពាក្យបណ្តឹងទាមទារសំណងមានអាចបត់បែនបាន និងមានជម្រើសច្រើន ដែលអនុញ្ញាតអោយអ្នកទាមទារសំណងធ្វើការជ្រើសរើសកម្មវិធីណាដែលស្របទៅនឹងតម្រូវការរបស់ពួកគេ។

បន្ទាប់ពីការបញ្ជូនពាក្យបណ្តឹងទាមទារសំណង ដែលទទួលខុសត្រូវដោយក្រុមហ៊ុនប្រេងប៊ីភី BP នោះស្ថាប័ន GCCF បានបង្ហាញនូវកម្មវិធីទូទាត់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់ ដែលត្រូវរចនាឡើងដើម្បីផ្តល់ជូនការទូទាត់សំណងបណ្តោះអាសន្នជាមួយនឹងការបំពេញតាមតម្រូវការឯកសារអប្បបរមាបានទាន់ពេលវេលា។

តាមរយៈកម្មវិធីទូទាត់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់

អ្នកទាមទារសំណងអាចស្វែងរកបានការខាតបង់ទាំងស្រុងអាចដល់ទៅរយៈពេលប្រាំមួយខែ

រួមមានការខាតបង់ដែលនឹងកើតឡើងជាមួយភស្តុតាងដែលបានកាត់បន្ថយ។

មិនតម្រូវអោយអ្នកទាមទារសំណងចុះហត្ថលេខាឈប់ប្តឹងទាមទារសំណង

ឬបដិសេធសិទ្ធិទទួលខុសត្រូវដើម្បីទទួលបានការទូទាត់សំណងជាមុនសម្រាប់តម្រូវការបន្ទា

ន់។ ស្ថាប័ន GCCF បានចំណាយប្រាក់ច្រើនជាង 2.58

កោដុល្លារសម្រាប់ការទូទាត់សំណងជាមុនចំពោះតម្រូវការបន្ទាន់ដល់ទៅអ្នកទាមទារសំណ

ងច្រើនជាង169,000 នាក់។

យោងតាមនាទីចុងក្រោយរបស់កម្មវិធីទូទាត់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់ស្ថាប័ន GCCF បានបង្កើតកម្មវិធីអ្នកទាមទារសំណងមិនមានតម្រូវការបន្ទាន់របស់ខ្លួនដែលផ្តល់ជូនដល់អ្នកទាមទារសំណងនូវជម្រើសជាច្រើន។ អ្នកទាមទារសំណងដ៏ទៃទៀតដែលគ្មានបំណងចង់ដោះស្រាយពាក្យបណ្តឹងទាមទារសំណងរបស់ពួកគាត់មានជម្រើសក្នុងការដាក់ពាក្យបណ្តឹងបណ្តោះអាសន្នដែលអនុញ្ញាតអោយស្វែងរកការស្តារឡើងវិញនូវការខាតបង់សមស្របនិងការខាតបង់ក្នុងពេលកន្លងមក។ អ្នកទាមទារសំណងដែលត្រូវបានទូទាត់ចំនួនទឹកប្រាក់បណ្តោះអាសន្ននោះមិនបានចុះហត្ថលេខាឈប់ទាមទារ ឬបដិសេដសិទ្ធិទទួលខុសត្រូវ ហើយអាចដាក់ពាក្យបណ្តឹងបណ្តោះអាសន្នបន្ថែម ឬពាក្យបណ្តឹងចុងក្រោយនៅពេលអនាគតបាន ។

អ្នកទាមទារសំណងទាំងនោះ ដែលមានបំណងជាក់ស្តែងដើម្បីដោះស្រាយពាក្យបណ្តឹងទាមទារសំណងរបស់ខ្លួននៅពេលនេះ អាចផ្ញើពាក្យបណ្តឹងស្របច្បាប់របស់ពួកគេ

និងទទួលបានការផ្តល់ជូនការទូទាត់សំណាងជាលក្ខណៈបុគ្គលពីស្ថាប័ន GCCF។ ក្រៅពីនេះ អ្នកទាមទារសំណាងដែលបានទទួលការទូទាត់សំណាងជាមុនសម្រាប់តម្រូវការបន្ទាន់កាលពីលើកមុនមានជម្រើសបន្ថែមក្នុងទទួលយក "ការទូទាត់សំណាងឆាប់រហ័ស" ដែលល្មមទៅនឹងការទូទាត់សំណាងសម្រាប់អ្នកទាមទារសំណាងបុគ្គល 5,000 ដុល្លារ និង សំណាងអាជីកម្ម 25,000 ដុល្លារ ដោយគ្មានការទាមទារនូវភាពសមស្របបន្ថែមណាទៀតទេ។ រាល់អ្នកទាមទារសំណាងណាមួយ ដែលមិនពេញចិត្តជាមួយការផ្តល់ជូនចុងក្រោយរបស់ស្ថាប័ន GCCF អាចធ្វើការបដិសេធចោលការប្រគល់ជូន ក្នុងលក្ខខណ្ឌដែលអ្នកទាមទារសំណាងពេញចិត្តទៅនឹងតម្រូវការឯកសារផ្នែកច្បាប់ដែលមានជាធរមាន អាចដាក់ពាក្យបណ្តឹងទៅមូលនិធិទំនុកចិត្តលើការទទួលខុសត្រូវចំពោះការធ្លាយប្រេងសហព័ន្ធ ឬចូលរួមក្នុងក្តីវិវាទនេះ។

ការបរិយាយប្រាប់ទាំងអស់នេះ នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ 2011 គឺស្ថាប័ន GCCF បានចំណាយជាង4.5 កោដដុល្លារ ដើម្បីទូទាត់សងទៅអោយអ្នកទាមទារសំណាងជាង 195,000

នាក់ ហើយបានផ្តល់ជូនការទូទាត់សំណងបន្ថែមទៀតប្រមាណជា430 លានដុល្លារទៀត ដែលការទូទាត់សងនេះសម្រាប់អ្នកទាមទារសំណងដែលកំពុងស្ថិតនៅក្រោមការពិនិត្យពិចារណា។

តាមរយៈវិធីសាស្រ្តចុងក្រោយរបស់ស្ថាប័ន GCCF ការទូទាត់សំណងសម្រាប់ពាក្យបណ្តឹងទាមទារសំណងចុងក្រោយមិនត្រឹមតែបញ្ចូលនូវការទូទាត់សងទៅលើការបាត់បង់ជាក់ស្តែង ដែលកើតឡើងនោះទេ ប៉ុន្តែវាថែមទាំងមានការទូទាត់សំណងទៅលើ "កត្តាអនាគតកាល" ដែលវាត្រូវបានបង្ហាញពីហានិភ័យ ក្នុងករណីណាមួយ ដូចជាការបាត់បង់នាពេលអនាគតដែលបណ្តាលមកពីការធ្លាយប្រេង។ នៅពេលស្ថាប័ន GCCF បញ្ចេញអោយប្រើវិធីសាស្រ្តចុងក្រោយរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ2011 គឺកត់សំគាល់ឃើញថា"[មាន]គឺជាភស្តុតាងនៃការអនុវត្តន៍ការស្តារសេដ្ឋកិច្ចឡើងវិញ" នៅក្នុងតំបន់ឈូងសមុទ្រ។ វិធីសាស្រ្តចុងក្រោយ 3។ ក្នុងការទទួលស្គាល់ពីធម្មជាតិប្រែប្រួលនៃការស្តារសេដ្ឋកិច្ច

ឡើងវិញ ស្ថាប័ន GCCF បានបញ្ជាក់ច្បាស់ថា

នឹងបន្តការវាយតម្លៃការងារសេដ្ឋកិច្ចក្នុងតំបន់ឈូងសមុទ្រ

និងធ្វើការកែសម្រួលកត្តាអានាគតកាលអោយបានសមស្រប:

> ការសន្និដ្ឋានរបស់ស្ថាប័ន GCCF
> បានផ្អែកលើមូលដ្ឋានទិន្នន័យបច្ចុប្បន្នភាព
> ជម្រើសរបស់អ្នកឯកទេស
> និងមតិយោបល់របស់អ្នកទាមទារសំណង
> និងដៃគូរចំណាប់អារម្មណ៍ផ្សេងទៀតក្នុងកំឡុងពេលនៃការផ្តល់
> មតិយោបល់ជាសាធារណៈ។ ស្ថាប័ន GCCF
> នឹងទទួលរ៉ាប់រងការវាយតម្លៃទិន្នន័យដែលមានស្រាប់ជាថ្មីឡើង
> វិញនៅរៀងរាល់បួនខែម្តង។ ប្រសិនបើ
> ការវាយតម្លៃឡើងវិញទាំងនេះផ្តល់នូវយោបល់ពីការប្រែប្រួលចំ
> ពោះការព្រួយបារម្មណ៍ក្នុងពេលអនាគតមិនមានភាពប្រាកដប្រ
> ជាណាមួយ
> ដែលចេញដីកាអោយមានការកែសម្រួលការទូទាត់សំណងស
> ម្រាប់ហានិភ័យពេលអនាគតកាល នោះស្ថាប័ន GCCF
> នឹងធ្វើការកែសម្រួលអោយបានសមស្រប
> និងនឹងអនុវត្តសម្រាប់រាល់ពាក្យបណ្តឹងទាំងឡាយណាដែលបា
> នផ្ញើមកតាមកាលបរិច្ឆេទខាងមុខនោះ។

វិធីសាស្រ្តចុងក្រោយ 3-4។

ក្រុមហ៊ុនប្រេងប៊ីភី BP

នៅតែប្តេជ្ញាចិត្តទូទាត់សំណងទៅអោយរាល់ពាក្យបណ្តឹងទាមទារសំណងស្របច្បាប់ដោយអ

នុលោមតាមច្បាប់ OPA។  ទោះជាយ៉ាងណាក្តី

បើយោងតាមសេដ្ឋកិច្ចតំបន់ឈូងសមុទ្ររដ្ឋបច្ចុប្បន្ន

គឺត្រូវតម្រូវអោយមានការអនុវត្តការវាយតម្លៃទៅលើកត្តាអនាគតកាលឡើងវិញនោះ។

បណ្តាញភស្តុតាងជាច្រើនបង្ហាញថា

ចំពោះក្របខណ្ឌដែលផ្នែកសេដ្ឋកិច្ចតំបន់ឈូងសមុទ្រត្រូវបានទទួលរងផលប៉ះពាល់ដោយ

សារការធ្លាយប្រេង  គឺការស្តារឡើងវិញត្រូវបានធ្វើឡើងនៅចុងឆ្នាំ 2010

ហើយកិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចជាវិជ្ជមានបន្តរហូតដល់ឆ្នាំ  2011

ដោយពិនិត្យទៅលើការវាស់វែងសេដ្ឋកិច្ចឆ្នាំ

2011ដែលលើសពីកិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចមុនពេលមានការធ្លាយប្រេង។

សេដ្ឋកិច្ចតំបន់ឈូងសមុទ្រកើនខ្ពស់ ហើយគ្មានមូលដ្ឋានណាសន្មតថាអ្នកទាមទារសំណង

ដែលមានករណីលើកលែងកំណត់

នឹងទទួលរងការខ្វះបាត់បង់ពាក់ព័ន្ធទៅនឹងការធ្លាយប្រេងពេលអនាគត

គឺត្រូវបានទុកជាភស្តុតាងដោយស្ថានភាពជាក់ស្តែងខាងក្រោម ក្នុងនោះរួមមាន:

> កំឡុងត្រីមាសដំបូងនៃឆ្នាំ 2011
> សណ្ឋាគារនៅតំបន់ឆ្នេរសមុទ្រនៃតំបន់ឈូងសមុទ្ររដ្ឋបានបំពេញការ

ងារយ៉ាងល្អ គឺល្អជាងកាលពីត្រីមាសដំបូង (មុនពេលធ្លាយប្រេង)
នៃកម្រិតឆ្នាំ 2010។

ការធ្វើអាជីវកម្មទេសចរណ៍នៅក្នុងតំបន់ឈូងសមុទ្របានរាយការណ៍មកថាមានសភាពល្អប្រសើរ ហើយក្នុងករណីខ្លះដូចជា ឯកត្តកម្ម និទាឃៈរដូវ ទិវារំឭកគុណចុងសប្តាហ៍ និងទិវាឈប់សម្រាកខែកក្កដាលើកទីបួន។

យោងតាមការិយាល័យភ្ញៀវទេសចរណ៍ និងសន្និសិទរដ្ឋ New Orleans
អ្នកទេសចរណ៍បានចំណាយប្រាក់ដុល្លារនៅក្នុងទីក្រុងកាលពីឆ្នាំ 2010 គឺខ្ពស់ ហើយខ្ពស់ជាងកាលពីឆ្នាំ 2009 ប្រហែលជា
ចំនួន 1.1 កោដដុល្លារ។

ដែននេសាទសមុទ្ររបស់សហព័ន្ធទាំងមូលត្រូវបានបើកដំណើរការ។

បន្ទាប់ពីការបើកអោយមានដំណើរការនេសាទនៅក្នុងរដូវក្តៅ
និងរដូវស្លឹកឈើជ្រុះឆ្នាំ 2010 ការនេសាទបង្គារ
និងត្រីសមុទ្រមានភាពប្រសើរឡើងខ្លាំង។

ការនេសាទបង្គារ និងត្រីសមុទ្រនៅតែមានភាពល្អប្រសើរក្នុងឆ្នាំ 2011។

ទិន្នន័យសេដ្ឋកិច្ចបច្ចុប្បន្នភាពមិនបានផ្តល់នូវគំនិតថា អ្នកទាមទារសំណងបុគ្គល និងអាជីវកម្មប្រឈមមុខនឹងហានិភ័យចំពោះការបាត់បង់ពេលអនាគតដោយសារតែការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon នេះទេ។ ដូច្នេះហើយ យោងតាមគោលការណ៍ដែលបានចែងនៅក្នុងវិធីសាស្រ្តចុងក្រោយរបស់ស្ថាប័ន GCCF គឺស្ថាប័ន GCCF គួរតែផ្អាកទូទាត់សំណងទៅលើកត្តាអនាគតកាល លើកលែងតែក្នុងកាលៈទេសៈកំណត់ណាមួយ (ប្រសិនបើមាន) ដែលជាទីកន្លែងសម្រាប់អ្នកនេសាទអយស្ទ័របង្កើតឡើង ហើយប្រេងនេះហៀរមកពីការធ្លាយនៅតំបន់ទឹកជ្រៅ Deepwater Horizon ដែលបានបំផ្លាញដែននេសាទរបស់អ្នកនេសាទអយស្ទ័រ។ ទោះជាមានទិន្នន័យសេដ្ឋកិច្ចក៏ដោយ ក៏អ្នកទាមទារសំណងមួយចំនួនដែលជឿថា ហានិភ័យនៃការបាត់បង់ពេលអនាគតគឺមិនអាចទទួលយកបាន មានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្ន ដែលផ្តល់ជូននូវការទូទាត់សំណងនៃការបាត់បង់សមស្របនាពេលកន្លងមកដោយគ្មានការចុះ

ហត្ថលេខាឈប់ទាមទារសំណងអ្វីឡើយ។

ខណៈពេលសមស្របដើម្បីរក្សាកត្តាអនាគតកាលសម្រាប់អ្នកនេសាទអយស្ទ័រ

(ប្រសិនបើមាន)

ដែលដែននេសាទទាំងនោះត្រូវបានបំផ្លាញដោយសារប្រេងហៀរមកពីការធ្លាយនៅតំបន់ទឹក

ជ្រៅ Deepwater Horizon

ការកែសម្រួលជាច្រើនត្រូវបានទាមទារអោយអនុវត្តដោយមានការពាក់ព័ន្ធទៅនឹងមធ្យាបាយ

ដែលស្ថាប័ន GCCF

អនុវត្តកត្តាអនាគតកាលចំពោះការនេសាទអយស្ទ័រប្រកបដោយភាពភាពអាជីពនេះ។

> ជាបញ្ហាផ្តើមដំបូងមួយ គឺជាការយល់ឃើញរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ដែលគ្មានអ្នកទាមទារសំណងណាមួយមានឯកសារណែនាំពីដែននេសាទអយស្ទ័រដែលរងគ្រោះដោយសារប្រេងហៀរមកពីការធ្លាយនៅតំបន់ទឹកជ្រៅ Deepwater Horizon នោះទេ។ គ្មានភស្តុតាងទាំងនេះ គឺស្ថាប័ន GCCF មិនអនុញ្ញាតអោយមានការទូទាត់សំណងទៅលើការខូចខាតណាមួយសម្រាប់ការបំផ្លាញដែននេសាទអយស្ទ័រឡើយ។
>
> វាគឺជាយល់ឃើញរបស់យើងថា ស្ថាប័ន GCCF កំពុងទូទាត់ប្រាក់សំណងទៅលើពាក្យបណ្តឹងសម្រាប់ការសាងសង់ឡូចញ៉ឹមអយស្ទ័រទាំងមូលដោយសារភាពប្រែប្រួលចរន្តទឹកសាបនៅឆ្នាំ 2010 រដ្ឋ Louisiana។ ក្រុមហ៊ុនប្រេងប៊ីភី BP មិនទទួលខុសត្រូវចំពោះសកម្មភាពរបស់រដ្ឋ Louisiana ទេ។ ហេតុដូច្នេះហើយ ស្ថាប័ន GCCF

មិនអាចទូទាត់សងទៅអោយអ្នកទាមទារសំណងបាននៅតាមកម្រិតណាមួយទេ ចំពោះការខូចខាតដោយសារតែមានភាពប្រែប្រួលមជ្ឈដ្ឋានទឹកស្អាត គឺអាចអនុញ្ញាតអោយធ្វើការតែងកងចំពោះកត្តាអនាគតកាលដែលត្រូវបានលើកកំពស់។

ថ្វីបើក្រុមហ៊ុនប្រេងប៊ីភី BP ទទួលខុសត្រូវចំពោះសកម្មភាពរបស់រដ្ឋ Louisiana និងការខូចខាតដែលបណ្តាលមកពី ភាពប្រែប្រួលចរន្តទឹកសាបរបស់រដ្ឋ នោះកត្តាអនាគតកាលដែលត្រូវបានលើកកំពស់នឹងអាចមានការទូទាត់សំណងជូនចំពោះតែអ្នកទាមទារសំណង ដែលអាចបង្ហាញភស្តុតាងពីការបំផ្លិចបំផ្លាញដោយភាពប្រែប្រួលចរន្តទឹកសាប។ ប៉ុន្តែ វាគឺជាយល់ឃើញរបស់យើងថា ស្ថាប័ន GCCF កំពុងអនុវត្តកត្តាអនាគតកាលដែលត្រូវបានលើកកំពស់សម្រាប់ពាក្យបណ្តឹងទាមទារសំណងទាំងអស់របស់អ្នកនេសាទអយស្ទ័រ និងអ្នកគ្រប់គ្រងដំណើរការអាជីវកម្មនេសាទ ថ្វីបើជាទីកន្លែងរបស់ពួកគេក៏ដោយ។ ដូច្នេះ យើងយល់ឃើញថាស្ថាប័ន GCCF កំពុងទូទាត់សំណងទៅលើកត្តាអនាគត 300% ទៅអោយអ្នកនេសាទអយស្ទ័រ នៅក្នុងរដ្ឋ Florida និង Alabama ទោះបីជាមានការជជែកជំទាស់ថា ដែននេសាទរបស់ពួកគេមិនត្រូវបានទទួលរងដោយសារភាពប្រែប្រួលមជ្ឈដ្ឋានទឹកស្អាតក៏ដោយ។ នេះគឺជាការមិនត្រឹមត្រូវ។

ក្រៅពីបញ្ហាកត្តាអនាគតកាល

មានបញ្ហាជាច្រើនផ្សេងទៀតមានការពាក់ព័ន្ធទៅនឹងមធ្យាបាយ ដែលស្ថាប័ន GCCF

ធ្វើការកំណត់ពីមូលហេតុ និងការខូចខាត ដែលតម្រូវអោយមានការវាយតម្លៃ

និងកែតម្រូវឡើងវិញ។ ស្ថាប័ន GCCF

មានសិទ្ធិទូលំទូលាយគួរអោយកត់សំគាល់នៅក្នុងការរៀបចំរចនានិតិក្រមពាក្យបណ្តឹងទាមទារ

សំណាងរបស់ខ្លួន

ប៉ុន្តែគ្មានសិទ្ធិសម្រេចអោយមានការទូទាត់សងដោយមិនកំណត់ចំពោះក្របខណ្ឌនៃច្បាប់

OPA ទេ។ ស្ថាប័ន GCCF បានពណ៌នាពីតួនាទីរបស់ខ្លួនដូចខាងក្រោម: លោក Feinberg

និងស្ថាប័ន GCCFដើរតួ និងជាតំណាងអោយ ក្រុមហ៊ុន BP Exploration & Production

ក្នុងការបំពេញកាតព្វកិច្ចលក្ខន្តិកៈរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ដែលជា 'ដៃគូរទទួលបន្ទុក'

ដោយអនុលោមតាម

ច្បាប់កង្វក់នៃប្រេងឆ្នាំ 1990។"1
នឹងជាដៃគូរក្នុងការបំពេញកាតព្វកិច្ចលក្ខន្តិកៈរបស់ក្រុមមហ៊ុនប្រេងប៊ីភី BP អនុលោមតាមច្បាប់
OPA ហើយស្ថាប័ន GCCF

ត្រូវតែទូទាត់សំណាងទៅអោយពាក្យបណ្តឹងទាំងឡាយណា

ដែលពេញលក្ខណៈក្នុងការទទួលយកការទូទាត់សងដោយអនុលោមតាមច្បាប់ OPA

ហើយត្រូវបដិសេធចំពោះពាក្យបណ្ដឹងទាមទារសំណងទាំងឡាយណា

ដែលមិនពេញលក្ខណៈក្នុងការទទួលយកការទូទាត់សងដោយអនុលោមតាមច្បាប់ OPA។

ដូចគ្នានេះដែរ

សម្រាប់ពាក្យបណ្ដឹងទាមទារសំណងទាំងឡាយណាដែលបានបំពេញនូវតម្រូវការរបស់ច្បាប់

OPA គឺចំនួនប្រាក់ដែលត្រូវទូទាត់សងត្រូវបានគ្រប់គ្រងដោយច្បាប់ OPA។

ក្នុងកាលៈទេសៈខ្លះ

ដោយមានកិច្ចប្រឹងប្រែងដ៏ប្រាកដមួយដើម្បីដោះស្រាយពាក្យបណ្ដឹងទាមទារសំណងអោយបា

នច្រើនបើអាចធ្វើទៅបាន ស្ថាប័ន GCCF

បានពន្យារប្រព័ន្ធនៃការទូទាត់សងដូចដែរបានចែងដោយច្បាប់ OPA

ហើយរហូតដល់ពេលទូទាត់សងដែលស្ថាប័ន GCCF ត្រូវបានផ្ដល់សិទ្ធិក្នុងសម្រេច។

ដូច្នេះហើយ មានការទូទាត់សំណងពាក់ព័ន្ធទៅនឹងពាក្យបណ្ដឹងទាមទារសំណង

ដែលអ្នកទាមទារសំណងគ្មានសិទ្ធិទទួលបានការទូទាត់សងណាមួយដែលអនុលោមតាមច្បាប់

OPA ឬអ្នកទាមទារសំណងត្រូវបានផុតរយៈពេលទូទាត់សង។ ខណៈពេល ក្រុមហ៊ុនប្រេងប៊ីភី

BP ចែករំលែកគោលបំណងក្នុងការដោះស្រាយរាល់ពាក្យបណ្ដឹងទាមទារសំណងស្របច្បាប់

នោះសំណួរពាក់ព័ន្ធទៅនឹងការទូទាត់សង

និងចំនួននៃការខូចខាតគឺត្រូវបានគ្រប់គ្រងដោយច្បាប់ OPA។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេប បញ្ជីមិនពេញលេញចែងពីវិធីដែលស្ថាប័ន GCCF

អនុវត្ត ជូនកាលស្ថិតនៅក្រោមការកំណត់របស់ច្បាប់ OPA

ដូច្នេះហើយវាលើសពីការផ្តល់សិទ្ធិរបស់ខ្លួន។

ក្នុងករណីណាមួយ យើងយល់ឃើញថាស្ថាប័ន GCCF កំពុងទូទាត់សំណងទៅលើការខូចខាតដោយមិនបានធ្វើការប៉ាន់ប្រមាណថាតើការបាត់បង់ស្របច្បាប់ពិតជាត្រូវបានបណ្តាលមកការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon ឬទេ។ នេះបានបង្ហាញនូវលទ្ធផលក្នុងការទូទាត់សំណងទៅអោយអ្នកទាមទារសំណង ដែលមានទីតាំងភូមិសាស្ត្រ និង/ឬសេដ្ឋកិច្ចឆ្ងាយពីតំបន់ដែលមានការធ្លាយប្រេង រាប់បញ្ចូលនូវសណ្ឋាគារមានទីតាំងនៅឯ Baton Rouge រដ្ឋ Louisiana និង Corpus Christi រដ្ឋ Texas ក្រុមហ៊ុនសំណង់នៅក្នុងរដ្ឋ Florida Keys រោងចក្រផលិតសម្ភារះដំបូលផ្ទះ ក្រុមហ៊ុនជួសជុលកញ្ចក់ ក្រុមហ៊ុន

---

1 ទំព័រដើមរបស់ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ *អាចចូលបានតាមរយះគេហទំព័រ* http://www.gulfcoastclaimsfacility.com/index (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011)។

ដោះដូរផ្ទះសម្បែង និងហាងតុបតែងលំអរសួនច្បារ ផ្សេងៗទៀត។

ក្នុងករណីខ្លះ ស្ថាប័ន GCCF បានបង្ហាញភស្តុតាងពេលឥឡូវដើម្បីសអោយឃើញពីកិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចកាលពីពេលកន្លងមក។ មានករណីច្រើន ដែលកិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចនៅឆ្នាំ 2009 របស់អ្នកទាមទារសំណង ក៏ដូចជានៅឆ្នាំខែមករា-មេសា ឆ្នាំ2010 ទាបជាងបើធៀបទៅនឹងឆ្នាំ 2008 និងខែមករា-មេសា ឆ្នាំ2009 តែស្ថាប័ន GCCF សន្មតយ៉ាងសមញ្ញថា នៅឆ្នាំ2010 បើគ្មានវត្តមាននៃការធ្លាយប្រេងទេ វានឹងមានកើនឡើងខ្ពស់។

ក្នុងករណីផ្សេងទៀតដែលគ្មានភស្តុតាងគាំទ្រនោះ ស្ថាប័ន GCCF បានសន្មតថា ការប្រសើរឡើងគួរអោយកត់សំគាល់នៅក្នុងកិច្ចប្រឹងប្រែងរបស់អ្នកទាមទារសំណងនៅឆ្នាំ 2009 ធៀបទៅ ឆ្នាំ 2008 គឺស្មើពីរដងនៃឆ្នាំ 2010 ប៉ុន្តែសម្រាប់ការធ្លាយប្រេង។ ក្នុងករណីខ្លះ ស្ថានភាពជាក់ស្តែងដោយឡែកជុំវិញពាក្យបណ្តឹងទាមទារសំណងមិនបានគាំទ្រការសន្មតនេះទេ។ បញ្ហាទាំងនេះមិនបានលើកឡើងសមស្របតាមរយៈការសន្មតជារួមមួយនេះទេ ប៉ុន្តែត្រូវតែជំនួសដោយការវាយតម្លៃ ផ្អែកទៅលើស្ថានភាពជាក់លាក់របស់ពាក្យបណ្តឹងទាមទារសំណង។

ដូចដែលការ ទាមទារដោយច្បាប់ OPA ស្ថាប័ន GCCF មិនបានទូទាត់សងសម្រាប់ប្រាក់ចំណូលដែលរកបានដោយអ្នកទាមទារសំណងនៅក្នុងកម្មវិធីផ្តល់ឱកាសក្នុងការប្រមូលប្រេង។

សរុបសេចក្តីមក ក្នុងខណៈដែល ស្ថាប័ន GCCF មានលក្ខណៈពេញលេញ

ហើយស្របទៅតាមតម្រូវការនិតិក្រមរបស់ច្បាប់ OPA ក្នុងរយៈពេលដ៏ខ្លីមួយ

វាគួរតែធ្វើការវាយតម្លៃពីកត្តាអនាគតឡើងវិញ

និងកែតម្រូវទិដ្ឋភាពនៃដំណើរការទូទាត់សងរបស់ខ្លួនទាំងនេះ ដែលវាមិនស្របទៅតាមច្បាប់

OPA ទេ។

I. **មិនបានអនុញ្ញាតអោយមានកត្តាអនាគត**
**ការកើនឡើងដ៏ចំលែកនៃសេដ្ឋកិច្ចតំបន់ឈូងសមុទ្រ**

ភស្តុតាងជាច្រើនបានបង្ហាញថា

ក្របខណ្ឌណាមួយនៃផ្នែកសេដ្ឋកិច្ចនៅតាមឈូងសមុទ្រត្រូវបានទទួលរងផលប៉ះពាល់ដោយ

សារការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon

សេដ្ឋកិច្ចឈូងសមុទ្រធ្លាប់បានឆ្លងកាត់នូវការស្តារយ៉ាងពេញទំហឹងមួយកាលពីរដូវស្លឹកឈើ

ជ្រុះឆ្នាំ 2010 ហើយកិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចនៅតែមានការប្រសើរឡើងក្នុងឆ្នាំ 2011។

A. ឧស្សាហកម្មទេសចរណ៍

1. ទិន្នន័យសណ្ឋាគារ

ឧស្សាហកម្មសណ្ឋាគារធ្វើការវាស់វែងសណ្ឋាគារដោយការវាយតម្លៃមានភ្ជាប់ជាមួយ

នឹងឥទ្ធិពលនៃកន្លែងស្នាក់នៅ និងអត្រាស្នាក់នៅក្នុងបន្ទប់។

ផលទុនដែលបានវាស់វែងនៅតាមបន្ទប់ស្នាក់នៅ ("RevPAR")

គឺជាការវាស់វែងពេញនិយមមួយ

ដែលត្រូវបានប្រើដោយឧស្សាហកម្មសណ្ឋាគារដើម្បីប៉ាន់ប្រមាណពីកិច្ចការស្តារសេដ្ឋកិច្ចពា

ក់ព័ន្ធឡើងវិញ។ ដ្យាក្រាមខាងក្រោមបង្ហាញថា RevPAR

នៅក្នុងតំបន់ឆ្នេរសមុទ្រសម្រាប់ត្រីមាសទីបួននៃឆ្នាំ 2010 បានកើនឡើងខ្ពស់ជាង

RevPAR សម្រាប់ត្រីមាសទីបួននៃឆ្នាំ 2009។ ក្រៅពីនេះ

ចំពោះក្រុមខណ្ឌផ្នែកឧស្សាហកម្មសណ្ឋាគារនៅតាមឈូងសមុទ្រម៉ិកស៊ិកត្រូវបានទទួលរងផ

លប៉ះពាល់ដោយសារការធ្លាយប្រេង កិច្ចប្រឹងប្រែងស្ដារបានត្រលប់ទៅ

កម្រិតនៃឆ្នាំ 2009 មុនរដូវស្លឹកឈើជ្រុះនៃឆ្នាំ 2010។

**កិច្ចប្រឹងប្រែងក្នុងត្រីមាស RevPAR (%ផ្លាស់ប្ដូរ vs. កំឡុងពេលដូចគ្នានៃឆ្នាំមុន)2**

| តំបន់ឆ្នេរសមុទ្រ | នៅក្នុងត្រីមាសទីបួននៃឆ្នាំ 2010 មានការកើនឡើង RevPAR |
|---|---|
| Louisiana | 10.4% |
| Mississippi | 10.8% |
| Alabama | 20.8% |
| Florida Panhandle | 5.4% |

អ្នកប្រឹក្សាយោបល់របស់ស្ថាប័ន GCCF គឺ ARPC

បានចេញនូវសេចក្ដីសន្និដ្ឋានដូចគ្នានេះនៅក្នុងរបាយការណ៍មួយ

ដែលចេញជាមួយនឹងវិធីសាស្ត្រចុងក្រោយរបស់ស្ថាប័ន GCCF ដែរ។ ជាពិសេស ARPC

បានវិភាគផលទុនដែលរកបានរបស់សណ្ឋាគារក្នុងចំងាយមួយម៉ាយនៃឆ្នេរឈូងសមុទ្រម៉ិកស៊ិក

កំឡុងពេលខែកញ្ញា-តុលា ឆ្នាំ 2010 មានការជាប់ពាក់ព័ន្ធទៅនឹងខែកញ្ញា-តុលា ឆ្នាំ 2009។

នៅគ្រប់ទីកន្លែងដែលបានធ្វើការវាយតម្លៃដោយ ARPC ផលទុនដែលរកបានសម្រាប់ខែកញ្ញា-

តុលា ឆ្នាំ 2010

ខ្ពស់ជាងឆ្នាំ 2009។[3]

កិច្ចប្រឹងប្រែងស្តារបានប្រសើរឡើងខ្លាំងនៅក្នុងឧស្សាហាកម្មសណ្ឋាគារនៃតំបន់ឈូងសមុទ្របានបន្តរហូតដល់ត្រីមាសដំបូងនៃឆ្នាំ2011។ កំឡុងត្រីមាសដំបូងនៃឆ្នាំ 2011 សណ្ឋាគារនៅតាមឆ្នេរសមុទ្រក្នុងតំបន់ឈូងសមុទ្ររដ្ឋធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍ RevPAR លើកម្រិតនៃត្រីមាសដំបូងឆ្នាំ 2010។

---

2 តំបន់ឆ្នេរសមុទ្រត្រូវបានដាក់បញ្ចូលព្រំប្រទល់ខណ្ឌជាប់ទៅនឹងឆ្នេរជាប់ឈូងសមុទ្រនៃរដ្ឋរបស់ពួកគេរៀងៗខ្លួន ដែលទិន្នន័យ RevPAR អាចមាន។ ប្រភព: ទិន្នន័យរបស់ Smith Travel

3 ARPC "ការវាស់វែងពីឥទ្ធិពលនៃការធ្លាយប្រេងនៅតំបន់ឈូងសមុទ្រទៅលើអ្នកទាមទារសំណងបុគ្គល និងអាជីវកម្ម និង ស៊ិចម៉ាការទូទាត់សងសំណងដែលបានស្នើសុំ" ថ្ងៃទី 24 ខែមករា ឆ្នាំ2011 នៅចំនុច 10។

### កិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចប្រចាំត្រីមាស RevPAR
### (%ផ្លាស់ប្តូរ vs. កំឡុងពេលជាមួយគ្នានៃឆ្នាំមុន)4

| តំបន់ឆ្នេរសមុទ្រ | នៅក្នុងត្រីមាសដំបូងនៃឆ្នាំ 2011 មានការកើនឡើង RevPAR |
|---|---|
| Louisiana | 9.8% |
| Mississippi | 5.3% |
| Alabama | 8.4% |
| Florida Panhandle | 6.4% |

2. <u>របាយការណ៍សារព័ត៌មាន</u>

សេចក្តីថ្លែងការណ៍ចេញដោយម្ចាស់អាជីវកម្ម និងស្ថាប័នពាក់ព័ន្ធ ដែលបានដាក់បញ្ចូលជាមួយបញ្ហាទេសចរណ៍បានថ្លែងអះអាងជាថ្មីពីអ្វីដែលទិន្នន័យបង្ហាញ គឺថាវិស័យទេសចរណ៍មានការប្រសើរឡើងខ្លាំង។ ខាងក្រោមនេះគឺជាការជ្រើសរើសការដកស្រង់មួយពីប្រភពរបាយការណ៍សារព័ត៌មាននាពេលថ្មីៗ:

Florida Panhandle - *សារព័ត៌មានប្រចាំថ្ងៃនៃរដ្ឋ Florida ភាគពាយ័ព្យ* "តួលេខគឺ: អ្នកទេសចរណ៍នៅផ្នែកខាងក្រោយ" ថ្ងៃទី7 ខែមិថុនា ឆ្នាំ 2011

- "ភ្នាក់ងារអភិវឌ្ឍន៍អ្នកទេសចរណ៍នៅខណ្ឌ Okaloosa Santa Rosa និង Walton ថ្មីៗនេះបានផ្សាយចេញនូវទិន្នន័យប្រមូលពន្ធដែននេសាទរបស់ពួកគេក្នុងខែមេសា ហើយខណ្ឌទាំងបីបានបិទផ្សាយពីកំនើនដ៏សម្បើមនេះ។ ការប្រមូលពន្ធដែននេសាទកើនដល់ 8.79 ភាគរយនៅក្នុងខណ្ឌ Okaloosa 21ភាគរយនៅខណ្ឌ Santa Rosa និង18.85ភាគរយ នៅខណ្ឌ Walton។"

- "លោក Dawn Moliterno ដែលជានាយកក្រុមប្រឹក្សាអភិវឌ្ឍន៍អ្នកទេសចរណ៍នៅស្រុក South Walton មានប្រសាសន៍ថា 'យើងមានកំនើនដ៏គួរអោយកត់សំគាល់ ហើយមាការរំភើបយ៉ាងក្រៃលែងអំពីតួលេខទាំងនោះដែលបាន និងបន្តឮដំណឹងល្អពីរដូវកាល ការកក់កន្លែង និងកក់សំបុត្រកំពុងតែមានមានចលនាស្ថិតភាព។' "

- "ក្រៅពីកំនើនតួលេខកាលពីខែមេសាកន្លង លោក Mark Bellinger នាយកប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍អ្នកទេសចរណ៍នៅស្រុក Okaloosa មានប្រសាសន៍ថា សម្រាប់ខែមេសា ឆ្នាំ2011 ក៏ធ្វើបានល្អជាងកាលពីខែមេសាឆ្នាំ 2009 និង 2008 ផងដែរ។"

---

[4] តំបន់ឆ្នេរសមុទ្រត្រូវបានដាក់បញ្ចូលព្រំប្រទល់ខណ្ឌជាប់ទៅនឹងឆ្នេរជាប់ឈូងសមុទ្រនៃរដ្ឋរបស់ពួកគេរៀងៗខ្លួន ដែលទិន្នន័យ RevPAR អាចមាន។ ប្រភព: ទិន្នន័យរបស់ Smith Travel

Florida Panhandle - *WTVY-TV* "ទិវារំឭកគុណបាននាំអាជីវកម្មមកតំបន់ឆ្នេរជាប់ឈូងសមុទ្រ " ថ្ងៃទី 1 ខែមិថុនា 2011

- "ទើបតែខ្ពស់ជាងមួយឆ្នាំ ចាប់តាំងពីមានការធ្លាយប្រេងរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ហើយអាជីវកម្មនេះមានការមមាញឹកជាងពីមុន។ អាជីកម្មនៅតាមឆ្នេរជាប់ឈូងសមុទ្រទាំងអស់នឹងចាប់ផ្តើមសំលឹងមើលឃើញនូវកំនើនខាងវិស័យទេសចរណ៍។ 'ខ្ញុំគិតថា ឆ្នាំនេះគឺជាឆ្នាំមួយ ក្នុងចំណោមឆ្នាំដែលមមាញឹកបំផុតផ្សេងទៀត។ ខ្ញុំគិតថា ប្រជាពលរដ្ឋដឹងថា ប្រេងលែងមានវត្តមាននៅទីនេះទៀតហើយ ហើយពួកគេនឹងធ្វើដំណើរមកទីនេះ។' [sic] អ្នកគ្រប់គ្រងទូកក្តោង Christian Whitehouse មានប្រសាសន៍ថា។ តាមរយៈវិស័យទេសចរណ៍ផ្លូវការរដ្ឋ Florida ចំនួនអ្នកទេសចរណ៍នឹងមកកំសាន្តនៅតាមឆ្នេរសមុទត្រូវបានរំពឹងទុកថាកើននៅចុងឆ្នាំនេះ។ 'យើងលែងរន្ធត់ពីព្រឹត្តិការណ៍ដ៏អាក្រក់កាលពីឆ្នាំកន្លងទៅដែលមានការធ្លាយប្រេង តែឆ្នាំនេះជាឆ្នាំដ៏មានអត្ថន័យ និងមានភាពប្រសើរឡើងយ៉ាងជាក់ច្បាស់' Whitehouse មានប្រសាសន៍ថា។"

សារព័ត៌មាន Pensacola - *Pensacola Florida* "ឯកតកម្មប្រចាំសប្តាហ៍ជាសញ្ញាដ៏ល្អមួយសម្រាប់រដូវកាលឆ្នេរសមុទ្រឆ្នាំ 2011" ថ្ងៃទី30 ខែឧសភា ឆ្នាំ 2011

- "'វាគឺជាសប្តាហ៍ដ៏អស្ចារ្យមួយ។ យើងកើនដល់ 60 ភាគរយសម្រាប់ចុងសប្តាហ៍ ហើយ 30 ភាគរយសម្រាប់ខែនេះ' Jeff Elbert ដែលជាម្ចាស់ហាងតាមឆ្នេរសមុទ្រ Island Style មានប្រសាសន៍។ 'យើងឮសូរភាពអ៊ូអរពេញមួយថ្ងៃ ហើយយើងនៅតែឮ (ថ្ងៃនេះ។) នេះគឺជាទិវារំឭកគុណចុងសប្តាហ៍ដ៏សប្បាយបំផុត ចាប់តាំងពីមុនមានព្យុះ Hurricane Ivan មកទល់សព្វថ្ងៃ។ ខ្ញុំមានសុទិដ្ឋិនិយមយ៉ាងខ្លាំងចំពោះចុងរដូវនេះ។'"
- យោងតាមការប៉ាន់ប្រមាណពីការដឹកជញ្ជូនរបាយការណ៍ដំបូងផ្តល់ជូនដោយឈ្មួញ និងផលទុននៅខែឧសភាបានប៉ាន់ប្រមាណ របៀតមកដល់ឥឡូវ 'ខែឧសភាគឺផុតទៅដោយមានការកត់សំគាល់ដ៏ប្រសើរមួយ'។[W.A. "Buck" Lee ដែលជានាយកប្រតិបត្តិអាជ្ញាធរកោះ Santa Rosa មានប្រសាសន៍ថា។ 'ខែឧសភាចាត់ទុកជាអ្នកបំបែកឯកត្តកម្មមួយ។ នេះគឺបន្ទាប់មកយើងមានខែមីនាល្អបំផុតរបស់យើង និងឯកត្តកម្មខែមេសា។'"

Gulf Shores Alabama -

local15tv.com"ការជួបជុំមានភាពកុះករនៅតាំឆ្នេរសមុទ្រសម្រាប់ការអបអរសាទរថ្ងៃទី4 ខែកក្កដា" ថ្ងៃទី 2 ខែកក្កដា ឆ្នាំ 2011

- "អ្នកដើរកំសាន្តតាមឆ្នេរសមុទ្របានជួបជុំកំសាន្តមាត់ច្រាំងជាប់ឈូងសមុទ្រ Gulf Shores នៅថ្ងៃសៅរ៍ដើម្បីអបអរសាទរថ្ងៃឯករាជ្យនៅតាមឆ្នេរជាប់ឈូងសមុទ្រ. . . . អ្នកទេសចរណ៍បានជួបជុំនៅតាមឆ្នេរសមុទ្រ. . . . សណ្ឋាគារ នឹងខុនដូរត្រូវបានដាក់ផ្តុំគ្នានៅតាមបណ្តោយមាត់ច្រាំងសមុទ្រ និងសួនច្បារ RV ពេញទៅដោយមនុស្សកុះករក្នុងកំឡុងពេលឈប់សំរាកចុងសប្តាហ៍។"

Gulf Shores, Alabama - *WKRG*, "ឯកត្តកម្មនៃភាពកុះករអាចមាននៅតាមឆ្នេរសមុទ្រ" ថ្ងៃទី1 ខែកក្កដា ឆ្នាំ 2011

- "ប្រសិនបើលោកអ្នកនៅតែកំពុងស្វែងរកខុនដូរ ឬបន្ទប់សណ្ឋាគានៅតាមមាត់ច្រាំងជាប់ឈូងសមុទ្រ Shores ឬ Orange ឆ្នេរសមុទ្រ លោកអ្នកអាចបាត់បង់សំណាង។ មនុស្សជាច្រើនបានកក់ពេញទាំងអស់។"

- "មន្ត្រីទេសចរណ៍ផ្លូវការនៅក្នុងខណ្ឌ Baldwin មានប្រសាសន៍ថា អត្រាស្នាក់នៅគឺជាជំហានដើម្បីរៀបចំឯកត្តកម្មថ្មី . . . [Kim Chapman ជាមួយនឹងមន្ត្រីទេសចរណ៍ឆ្នេរសមុទ្រ Gulf Shores/ Orange មានប្រសាសន៍ថា]
  'ឆ្នាំ 2007 គឺជាឆ្នាំល្អបំផុតរបស់យើង ហើយយើងកំពុងស្វែងរកតួលេខខ្ពស់ជាងនេះដែលកើតមានក្នុងឆ្នាំនេះ។ យើងសម្រេចបានទិសដៅរបស់យើង ហើយបន្តខំប្រឹងធ្វើការ និងសង្ឃឹមយ៉ាងមុតមាំថាយើងនឹងទទួលបាន ឬអាច ឈ្នះគេ។'"

**Gulf Shores, Alabama** - *al.com*, "ជាតំបន់ឆ្នេរជាប់ឈូងសមុទ្រ Gulf Shores និងឆ្នេរសមុទ្រ Orange លើកទីបួនមានចំនួនអ្នកទេសចរណ៍ ខែកក្កដាបានរំពឹងទុកថាកើនឡើងនៅឆ្នាំនេះ" ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2011

- "'យើងនឹងប្រឹងប្រែងអោយអស់ពីសមត្ថភាពដូចដែលយើងអាចធ្វើទៅបាន' Bill Brett នៃក្រុមហ៊ុន Brett Robinson មានប្រសាសន៍ ក្រុមហ៊ុនអភិវឌ្ឍន៍ និងអចលនទ្រព្យនៅក្នុងតំបន់ឆ្នេរសមុទ្រ Orange។ ក្រុមហ៊ុនកើនឡើងច្រើនជាង ការជួលចំនួន 2,000 កន្លែងគឺស្មើនឹង 95 ភាគរយដែលបានកក់ បើប្រៀបធៀបទៅនិង 80 ភាគរយនៅឆ្នាំ 2009។"
- "'ការផ្លាយប្រេងកាលពីឆ្នាំកន្លងទៅនេះគឺគ្មានបញ្ហាអ្វីទេ។ ដូច្នេះគ្មានការចង្អុលបង្ហាញអ្វីទេ' Brett មានប្រសាសន៍ថា"។
- "សណ្ឋាគារ Island House និងផ្ទះជួលលំហែរកាយវិស្សមកាលសម្រាប់ក្មេងៗ (Young's Suncoast Vacation Rentals) មានការកក់ 100 ភាគរយ បើយោងតាមអ្នកនាំពាក្យការិយាល័យទេសចរណ៍ Kim Chapman។ Kaiser Realty បានរាយការណ៍ថា មានការស្នាក់នៅចំនួន 93 ភាគរយ បើធៀបទៅនឹង 88 ភាគរយកាលពីឆ្នាំ 2009 អ្នកស្រីមានប្រសាសន៍។"

**Gulf Shores, Alabama** - *FOX10tv.com* "ទិវារំឭកគុណដល់ថ្ងៃធ្វើអាជីវកម្មនៅតាមឆ្នេរសមុទ្រ Baldwin" ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2011

- "Al Sawyer ជាម្ចាស់[នៃ] King Neptune's នៅតាមឆ្នេរជាប់ឈូងសមុទ្រ Gulf Shores មានប្រសាសន៍ថា ភាពអ៊ូអរមានច្រើនណាស់នៅចំថ្ងៃទិវារំឭកគុណចុងសប្តាហ៍។ 'ព្រហស្បតិ៍ សុក្រ សៅរ៍ អាទិត្យ . . . មានសុទ្ធតែមនុស្ស' Sawyer មានប្រសាសន៍ថា"
- " Sawyer មានប្រសាសន៍ថា គាត់មិនដែលឃើញទិវារំឭកគុណចុងសប្តាហ៍ដូចនេះទេ។ នៅពេលគាត់ទទួលបានតួលេខនេះ គាត់មានក្តីរំភើប។ 'ដំណឹងល្អ! កើនឡើង 33 ភាគរយ!' Sawyer បានស្រែកហ៊ោឡើង។ គឺកើនឡើង 33 ភាគរយ ខ្ពស់ជាងភាគរយមធ្យមក្នុងរយៈពេលបីឆ្នាំទៅទៀត។ ធ្វើអោយទិវារំឭកគុណនៅចុងសប្តាហ៍បានល្អបំផុត គាត់បានបើកភោជនីយដ្ឋាននេះរយៈពេល 18 ឆ្នាំហើយ។"
- "'យើងត្រូវការការចង្អុលបង្ហាញមួយ យើងនឹងមានអាជីកម្មរដូវក្តៅល្អមួយ។ វាហាក់ដូចជា យើងនឹងមានអាជីកម្មរដូវក្តៅដ៏មហាស្ចារ្យមួយអញ្ចឹង!' Sawyer មានប្រសាសន៍"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Alabama** - *Mobile Press-Register*,
"អាជីវកម្មតាមឆ្នេរសមុទ្ររបស់រដ្ឋ Alabama រំពឹងទុកថា
'មានស្ថានភាពជំនួញល្អពេញមួយរដូវក្តៅ'" ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2011

- "'Cindy Holden ជាអ្នកគ្រប់គ្រងបាអយស្ទ័រ និងគ្រឿងសមុទ្រ [Doc's Seafood Shack & Oyster Bar] មានប្រសាសន៍ថាមនុស្សច្រើនកុះករនៅពេលអាហារថ្ងៃត្រង់ ដែលចូលទៅខាងក្នុង រង់ចាំចូលអង្គុយតាមតុ។ 'ខ្ញុំគិតថា យើងនឹងទទួលបានរដូវឯកត្តកម្មនៅទីនេះ។'
  សម្រាប់អាជីវកម្មនៅតាមបណ្តោយឆ្នេរសមុទ្រ ទិវារំឭកគុណចុងសប្តាហ៍ពីធិបុណ្យនៅរដូវក្តៅ ក៏មានការតំណាងជាអ្នកចង្អុលបង្ហាញនូវរដូវកាលពេលខាងមុខ។ ហើយការឈប់សម្រាកចុងសប្តាហ៍បានបង្ហាញអោយឃើញពីសញ្ញាថាទេសចរណ៍នឹងមានទៅមកយ៉ាងខ្លាំងក្លាពីការធ្លាយប្រេងរបស់ក្រុមហ៊ុនប្រេងប៊ីភី BP កាលពីឆ្នាំកន្លងទៅ: ពីកៅអីក្នុងព្រះវិហារគ្រីស្តសាសនាដែលមានមនុស្សអង្គុយពេញនៅក្នុងព្រះវិហារ រហូតដល់កៅអីដែលមានអ្នកអង្គុយនៅតាមឆ្នេរសមុទ្រ ពីចំណតដែលបានរៀបចំនិងមានហាងលក់សម្ភារះស្នូចត្រី និងហាងលក់អីវ៉ាន់ច្រើន។
- "ក្រុមហ៊ុនផ្សេងទៀត[ជាច្រើន]ក៏បានរាយការណ៍ពីចំនួនឯកត្តកម្មនេះដែរ។"

- "'ប្រៀបធៀបទៅនឹងឆ្នាំកន្លងមក យើងបញ្ចូលចំនួនទាំងអស់នេះ' [Blake Blair ដែលជានយោជិកនៅឯ Blonde John's Surf & Skate] មានប្រសាសន៍។"

- "'ខ្ញុំគិតថាវានឹងក្លាយជារដូវក្តៅដ៏ធំបំផុត ដែលយើងមិនដែលមានពីមុនមក' Blair ដែលអ្នកនឹងមកដល់ហាងក្នុងនាមជាអតិថិជន និងជាកម្មករហូតដល់ពេលណាគាត់អាចចាំបាន។"

- "'យើងពិតមានសេចក្តីរីករាយនៅពេលមានអ្នករាល់គ្នា' [Jennifer Kaylor ជាអគ្គនាយកនៃបា និងភោជនីយដ្ឋាន Cosmo] មានប្រសាសន៍។ 'អាចអោយយើងដឹងថាពីទីនេះទៅខាងក្រៅ គឺរវល់ណាស់។'"

- "[ Frank Hughes ដែលជាម្ចាស់កោះ Adventure] បានកំពុងប៉ាន់ស្មានទុកពីការកើនឡើងកាលពេលឆ្នាំកន្លងទៅ។ 'យើងបានដឹងរួចទៅហើយ ថាវាប្រសើរជាង' គាត់មានប្រសាសន៍។"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Alabama** - *Mobile Press-Register* "អ្នកទេសចរណ៍កោះ Dauphin Island រៀបចំឆ្នេរសមុទ្រសម្រាប់

ទិវារំឭកគុណ" ថ្ងៃទី 31 ខែឧសភា ឆ្នាំ 2011

- "ចុងសប្តាហ៍—ប្រពៃណីចាប់ផ្តើមមាននៅរដូវក្តៅ — ជាពេលសំខាន់មួយសម្រាប់អាជីវកម្មតូចៗនៅលើកោះនោះ.... វាកើតឡើងដើម្បីទទួលជោគជ័យ។ បានកក់កន្លែងជួលសម្រាប់ស្នាក់នៅពេលវិស្សមកាល។ ភ្ញៀវបានធ្វើដំណើរចូល និងចេញពីហាង និងភោជនីដ្ឋានក្នុងតំបន់ ហើយបន្តទៅជួបជុំគ្នានៅតាមឆ្នេរសមុទ្រនៅល្ងាចថ្ងៃចន្ទ។"

- "Robin Linn ដែលជាលេងភាគហ៊ុន និងម្ចាស់អចលនទ្រព្យ ACP មានប្រសាសន៍រដិបរដុប 100 កន្លែង ថាក្រុមហ៊ុនរបស់នាងគ្រប់គ្រងនៅលើកោះ មានតែបីអាគារប៉ុណ្ណោះដែលគ្មានមនុស្សនៅចុងសប្តាហ៍។ គឺមួយភាគបីខ្ពស់ជាងឆ្នាំ2009 អ្នកស្រីមានប្រសាសន៍។"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Alabama** - *al.com,*

"អ្នកឯកទេសបានព្យាករណ៍ថាទិវារំឭកគុណនៅចុងសប្តាហ៍មានការមមាញឹក

សម្រាប់តំបន់ឆ្នេរសមុទ្រ Baldwin" ថ្ងៃទី 27 ខែឧសភា ឆ្នាំ 2011

- "'យើងនឹងប្រមូលយកទិន្នន័យដែលបានកត់ត្រាទាំងនោះ ដែលខុសពីប្រក្រតី' [ Emily Gonzalez ដែលជាអ្នកមានទ្រព្យអចលនវត្ថុ] មានប្រសាសន៍។ ប្រភេទទិវារំឭកគុណបោះជំហានទៅសម្រាប់អ្វីដែលយើងស្មានទុកនៅឆ្នាំនេះ និងរដូវកាលខាងមុខ។ នេះផ្តល់អោយយើងនូវការយល់ដឹងទាន់ហេតុការណ៍ច្រើនប្រកបដោយសុទិដ្ឋិនិយម។'"

- "'យើងស្ថិតនៅក្នុងរូបភាពល្អមួយ

ហើយប្រជាពលរដ្ឋត្រៀមខ្លួនជាស្រេចត្រលប់ទៅឆ្នេរសមុទ្រ ៉ [Tony Kennon ជាវរសេនីយត្រីនៃឆ្នេរសមុទ្រ Orange] មានប្រសាសន៍។ ៉មនុស្សជាច្រើនរាប់ពាន់នាក់បានធ្វើដំណើរមក។ ខ្ញុំមានសេចក្តីរំភើបចំពោះវា។ ហើយខ្ញុំមិនគិតថា មានអ្វីមួយត្រូវបារម្មណ៍ តាមដែលតួលេខកំពុងថយចុះ។៉៉

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Alabama** - *Local15tv.com*, ៉៉អាជីវកម្មតាមឆ្នេរសមុទ្រសំលឹងឃើញស្តង់សម្រាប់លំហែកាយនៅរដូវក្តៅ៉៉ ថ្ងៃទី1 ខែមេសា ឆ្នាំ2011

- ៉៉ជាមួយនឹងអនាម័យតាមឆ្នេរសមុទ្រ អាជីវកម្មកំពុងសង្ឃឹមទុកថាការសម្រាកលំហែកាយនៅរដូវក្តៅ និងអំពាវនាវទទួលយកការជូនពររបស់ពួកគេ។ អ្នកជួលកន្លែងស្នាក់នៅ និងភោជនីយដ្ឋានមានប្រសាសន៍ថា ពួកគេបានឃើញស្តង់ដ៏ធំមួយ។... ៉អតិថិជនរបស់យើងមានសេចក្តីសប្បាយរីករាយ ហើយយើងមានក៏មានការរំភើបពេលពួកគេត្រលប់មកវិញ ៉ Sarah Kuzma ជាមួយនឹង Meyer Realty មានប្រសាសន៍។ Kuzma មានប្រសាសន៍ថាការជួលកើនឡើងដល់ទៅ 30

ភាគរយគិតចាប់ពីពេលនេះនាឆ្នាំកន្លងទៅ។"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Mississippi** - *WLOX-TV*, "ឆ្នេរសមុទ្រ Biloxi បាននាំអ្នកទេសចរណ៍មកកំសាន្តសម្រាប់ទិវារំឭកគុណ" ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2011

- "មានមនុស្សច្រើនណាស់មកពីរដ្ឋ Alabama Louisiana Florida តាមពិតទៅមកពីរដ្ឋ Mississippi, Texas។ យើងមានភ្ញៀវមកពីក្រុង New York Cincinnati។ មានការធ្វើដំណើរទៅមក [sic] តាំងពីឆ្នាំកន្លងទៅ' Beach Bumps ដែលជាអ្នកគ្រប់គ្រង Caleb Heartfield មានប្រសាសន៍។"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Mississippi** - *WWL-TV*, "មនុស្សកុះករនៅចុងសប្តាហ៍ជាសញ្ញាអោយដឹងពីការត្រលប់មកវិញរបស់ភ្ញៀវទេសចរណ៍នៅក្នុងការប្រលងបវរកញ្ញា។ តំបន់ឆ្នេរជាប់ឈូងសមុទ្រ " ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2011

- "Biloxi -- ដូចជាសហគមន៍ឆ្នេរសមុទ្រជាច្រើនផ្សេងទៀតនៅតាមបណ្តោយមាត់ច្រាំងឆ្នេរសមុទ្រ--គឺមានការអ៊ូអរឡើងវិញ បន្ទាប់ពីមានការធ្លាយប្រេងរបស់ក្រុមហ៊ុនប្រេងប៊ីភី BP. . . 'ពន្ធភោជនីដ្ឋានបានកើនឡើង' Janice Jones បំរើការនៅការិយាល័យភ្ញៀវទេសចរណ៍ និងសន្និសិទតំបន់ឆ្នេរជាប់ឈូងសមុទ្រ Mississippi មានប្រសាសន៍។ 'ពន្ធទេសចរណ៍កើនឡើង។ រាល់ការចង្អុលបង្ហាញទាំងអស់គឺសុទ្ធតែវិជ្ជមាន។' Jones មានប្រសាសន៍ថា អត្រាស្នាក់នៅតាមសណ្ឋាគារនៅចុងសប្តាហ៍នេះបានកើនទៅដល់ 80 ភាគរយ។"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Mississippi** - *WGNO-TV*,"ឆ្នេរសមុទ្រ Gulf Coast បានចំនួនថយចុះ" ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2011

- "លោកវរសេនីយត្រី Bay St. Louis រំពឹងទុកថា នេះគឺជាឯកត្តកម្មក្នុង [sic] ឆ្នាំ. . . . 'យើងមានមហោស្រពស្ពានប្រចាំឆ្នាំរបស់យើងកាលពីចុងសប្តាហ៍មុន។ យើងមានមនុស្សច្រើនកុះករបំផុត ដែលធ្លាប់មានពីមុនពេលមានព្យុះ Katrina។ ប្រសិនបើនេះជាប្រភេទចង្អុលបង្ហាញ យើងអាចចាំមើលឆ្នាំបដាពី Bay St. Louis' [លោកវរសេនីយត្រី] សូមបំបេញឈ្មោះ មានប្រសាសន៍។"

**តំបន់ឆ្នេរជាប់ឈូងសមុទ្រ Louisiana** - *WGNO-TV*'ឆ្នេរសមុទ្រ Grand Isle

បានរៀបចំបើកអោយមានទិវារំឭកគុណនេះ

មួយឆ្នាំក្រោយពីមានការធ្លាយប្រេងរបស់ក្រុមហ៊ុនប្រេងប៊ីភី” ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2011

- “អាជីវកម្មបានចំរើនលូតលាស់នៅតាមភោជនីដ្ឋានជាច្រើនក្នុងតំបន់ឥឡូវឆ្នេរសមុទ្រត្រូវបានបើកអោយប្រើប្រាស់ឡើងវិញ។”
- “Missy Raum គឺជាអ្នកបម្រើស្រីនៅឯភោជនីដ្ឋាន Starfish ដែលមានភ្ញៀវចូលមកច្រើនកុះករនៅថ្ងៃនេះ គ្មានតុទំនេរទេ។”
- “‘គឺកំពុងទាក់ទាញវិស័យទេសចរណ៍ត្រលប់មកវិញ។ ឆ្នេរដ៏ស្រស់បំព្រងគួរជាទីគយគន់ យើងមានមនុស្សច្រើនកុះករ ហើយអ្នកទេសចរណ៍បានត្រលប់វិញ’ Raum មានប្រសាសន៍។”

**សារលិខិតចេញដោយអនុប្រធានាធិបតី សហប្រតិបត្តិការសាធារណៈ និងទំនាក់ទំនង នៃការិយាល័យភ្ញៀវទេសចរណ៍ និងសន្និសិទរដ្ឋ New Orleans (ថ្ងៃទី 15 ខែមេសា ឆ្នាំ 2011):**

- “បទពិសោធន៍ក្នុងការទស្សនារដ្ឋ New Orleans មិនមានការផ្លាស់ប្តូរទេ ហើយតាមពិតទៅមានការប្រសើរជាងពីមុនទៅទៀត។ រដ្ឋ New Orleans បានទទួលការលុបចោលចំនួនតិចតួចមែនទែន ឬបាត់បង់អាជីវកម្មទេសចរណ៍ដោយសារការធ្លាយប្រេង។ ជាក់ស្តែង រដ្ឋ New Orleans បានស្វាគមន៍អ្នកទេសចរណ៍ចំនួន 8.3 លាននាក់ក្នុងឆ្នាំ 2010 ស្មើនឹង 10.7 ភាគរយកើនឡើងធៀបទៅឆ្នាំ 2009 ហើយជាលើកដំបូងដែលឈានទៅដល់ចំនួនអ្នកទេសចរណ៍ 8 លាននាក់ ចាប់តាំងពីពេលមានព្យុះ Katrina។ អ្នកទេសចរណ៍ទាំង 8.3 លាននាក់នោះបានចំណាយប្រាក់ចំនួន 5.3 កោដដុល្លារ គឺកើនឡើងចំនួន 1.1កោដដុល្លារធៀបទៅ

ឆ្នាំ 2009 និងជាការចំណាយខ្ពស់បំផុតនៅក្នុងប្រវត្តិរបស់ទីក្រុងនេះបើយោងតាមការសិក្សាស្រាវជ្រាវដោយមជ្ឈមណ្ឌលស្រាវជ្រាវបដិសណ្ឋារកិច្ច UNO។"

- o "ឧស្សាហកម្មទេសចរណ៍រដ្ឋ New Orleans ក៏បានបញ្ចប់តួលេខឆ្នាំ 2010 ជាតួលេខឈានមុខគេនៃការមកដល់របស់ភ្ញៀវទេសចរណ៍នៅក្នុងប្រទេសសម្រាប់កំណើន REVPAR ពីមួយឆ្នាំទៅមួយឆ្នាំ ដែលយោងតាម Smith Travel។"

B. <u>ឧស្សាហកម្មនេសាទ</u>

ក្រោយពេលធ្លាយប្រេង ផ្នែកដែននេសាទអាជីវកម្មក្នុងតំបន់ឈូងសមុទ្រត្រូវបានបិទ។ ការបើកធ្វើអាជីវកម្មឡើងវិញបានចាប់ផ្តើមកំឡុងពេលរដូវក្តៅនៃឆ្នាំ 2010 ហើយភាគច្រើននៃដែននេសាទអាជីវកម្មទាំងអស់ត្រូវបានបើកអោយធ្វើអាជីវកម្មឡើងវិញនៅរដូវស្លឹកឈើជ្រុះឆ្នាំ 2010។ ដែននេសាទអាជីវកម្មសហព័ន្ធទាំងអស់បើកធ្វើអាជីកម្មពីពេលឥឡូវនេះទៅ។[5]

1. <u>សុវត្ថិភាពអាហារសមុទ្រ</u>

អាហារសមុទ្រក្នុងតំបន់ឈូងសមុទ្របានកំពុងធ្វើតេស្តសុវត្ថិភាពយ៉ាងទូលាយមួយដោយនិយតករសហព័ន្ធ ដែលបានកំណត់ថា វាមានសុវត្ថិភាពក្នុងការបរិភោគ។ ទាំង NOAA និងស្ថាប័នគ្រប់គ្រងថ្នាំ និងម្ហូបអាហារបានសន្និដ្ឋានយ៉ាងច្បាស់លាស់ថាអាហារសមុទ្រនៅក្នុងតំបន់ឈូងសមុទ្រគឺ

មានសុវត្ថិភាព។ NOAA បានដាក់ជាសំណួរ និងចម្លើយដូចខាងក្រោម: [6]

សំណួរ: តើលទ្ធផលនៃ[ការធ្វើតេស្ត] បង្ហាញពីអ្វី?

ចម្លើយ:
អាហារសមុទ្រក្នុងតំបន់ឈូងសមុទ្របានឆ្លងកាត់ការត្រួតពិនិត្យដោយប្រើការតេស្តទៅលើការហើរពណ៌។ សម្រាប់ការព្រួយបារម្មណ៍ពីកម្រិតអ៊ីដ្រូកាបូន 12 នីមួយៗត្រូវបានយកមកធ្វើតេស្តគឺមីអាហារសមុទ្រត្រូវបានធ្វើតេស្ត 100 ទៅ1000 ដង ឬទាបជាងកម្រិតដែលមិនអាចទទួលយកបានរបស់ FDA បានអោយដឹងថាជាកម្រិតព្រួយបារម្មណ៍។ <u>អ្នកឯកទេសខាងអាហារសមុទ្រមានភាពជឿជាក់ថាការសារធាតុបង្កអោយកង្វក់ដោយសារប្រេង ឬការបែកខ្ញែករបស់ប្រេង នឹងត្រូវបានធ្វើរឃើញដោយសារការធ្វើតេស្ត ហើយបង្ហាញយ៉ាងច្បាស់លាស់ថា អាហារសមុទ្រនៅតាមតំបន់ឈូងសមុទ្រគឺមានសុវត្ថិភាពសារធាតុបង្កអោយកង្វក់ដោយសារប្រេង ឬការ បែកខ្ញែករបស់ប្រេង។</u>

***

---

[5] ការបិទផ្សាយសារព័ត៌មាន NOAA: ដែនទឹកនៃតំបន់ឈូងសមុទ្រសហព័ន្ធទាំងអស់បានបិទមិនអោយនេសាទដោយសារតែការធ្លាយប្រេង (ថ្ងៃទី19 ខែមេសា ឆ្នាំ2011) *អាចចូលបានតាមរយៈគេហទំព័រ*http://www.restorethegulf.gov/release/2011/04/19/last-fisheries-re-opening-today (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 7 ខែឧសភា ឆ្នាំ2011).

[6] NOAA: សុវត្ថិភាពអាហារសមុទ្រក្នុងតំបន់ឈូងសមុទ្រ: លក្ខណៈមូលដ្ឋាន *អាចចូលបានតាមរយៈគេហទំព័រ*http://www.nmfs.noaa.gov/stories/2011/04/21_sea_food_safety.html (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011) (ចំនុចសំខាន់បានដាក់បញ្ចូល)។

សំណួរៈ
តើអាហារសមុទ្រក្នុងតំបន់ឈូងសមុទ្រមានសុវត្ថិភាពពីប្រមូលផ្តុំប្រេងដែរឬទេ?

ចម្លើយៈ បាទ។ អ្នកវិទ្យាសាស្ត្របានបង្ហាញភស្តុតាងថា ត្រីអាចបញ្ចេញចោលប្រេងទាំងនោះបានល្អជាងពួកគេកៀប្រមូលប្រេងដែលនៅសាយវាលទៀតផង ហើយកាលពីឆ្នាំមុន NOAA និងអ្នកវិទ្យាសាស្ត្រ FDA បានធ្វើតេស្តពិសោធន៍ ដែលអាចស៊ើបរកបរិមាណស្លាកស្នាមនៃប្រេងដែលនៅជាប់នឹងខ្លួនត្រីនោះ។ រាល់សំណាកនីមួយៗបានឆ្លងផុតនូវការធ្វើតេស្តមើល ប្រមាណជាង 99% នៃសំណាកមិនបានរកឃើញបរិមាណដែលគេចង់តេស្តមើលទេ– នេះគឺជាទាបជាងការកំណត់តេស្តមើលនៃឧបករណ៍រំញោចខ្ពស់។ <u>ដោយសារតែការខិតខំប្រឹងប្រែងរបស់ NOAA FDA និង អ្នកឯកទេសអាហារសមុទ្រប្រចាំរដ្ឋ និងសហប្រតិបត្តិការណ៍របស់អ្នកនេសាទក្នុងតំបន់ឈូងសមុទ្រ អ្នកប្រើប្រាសើអាចមានអារម្មណ៍ជឿជាក់ថាអាហារសមុទ្រក្នុងតំបន់ឈូងសមុទ្រមានសុវត្ថិភាពក្នុងការវិភាគ។</u>

ស្រដៀងគ្នានេះដែរ

ដើម្បីឆ្លយតបទៅនឹងសំណួរ"តើអាហារសមុទ្រដែលនេសាទបាននៅតាមតំបន់ឆ្នេរជាប់ឈូងសមុទ្រមានសុវត្ថភាពក្នុងការបរិភោគដែរឬទេ?"ស្ថាប័នគ្រប់គ្រងថ្នាំ និងម្ហូបអាហារបានឆ្លើយថាៈ "ត្រី និងគ្រឿងសមុទ្រដែលបានមកពីតំបន់នេសាទដែលទើបបើកអោយធ្វើអាជីវកម្ម ឬតំបន់ដែលមិនបានរងឥទ្ធិពលដោយការបញ្ឈប់អាជីវកម្មនេសាទត្រូវចាត់ទុកថាមានសុវត្ថិភា

ពសម្រាប់បរិភោគ ដូចដែលពួកគេធ្លាប់បរិភោគមមុនពេលមានការធ្លាយប្រេង។[7]

2. <u>ផលិតផលនេសាទ</u>

ទិន្នន័យផលិតផលត្រីដែលមានជាសាធារណៈបង្ហាញថា ការនេសាទត្រីសមុទ្រ

និងបង្គារមានការប្រសើរឡើងខ្លាំង

លុះត្រាតែដែននេសាទត្រូវបានបើកអោយធ្វើអាជីវកម្មឡើងវិញ។ ឧទាហរណ៍

បើយោងតាមទិន្នន័យ NOAA ខែធ្នូ

ឆ្នាំ 2010 គឺជាខែធ្នូដ៏ពិសេសមួយក្នុងរយៈពេលប្រាំឆ្នាំកន្លងមក
ជាមួយនឹងការពាក់ព័ន្ធទៅនឹងចំនួនសរុបទូកនេសាទបង្គារចូលចតផែនៅតាមតំបន់ឈូងសមុទ្រ។[8]

ខណៈពេលមានការប្លែកគ្នានៅក្នុងខែណាមួយ នៃរដ្ឋចំនួន ខែមករា-ឧសភា ឆ្នាំ 2011

គឺជារយៈពេលនៃខែមករា-

ឧសភាដែលមានផលិតផលបង្គារសរុបប្រសើរឡើងខ្លាំងបំផុតលើកទីពីរក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ។[9] ខែឧសភា ឆ្នាំ2011

គឺជាខែឧសភាដែលមានផលិតផលបង្គារប្រសើរឡើងខ្លាំងបំផុតនៅក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនីក្នុងរដ្ឋ Florida Texas Alabama និង

Mississippi។[10]

---

[7] FDA, ការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon: សំណួរ និង ចម្លើយ, *អាចចូលបានតាមរយៈគេហទំព័រ*http://www.fda.gov/Food/FoodSafety/Product-

SpecificInformation/Seafood/ucm221563.htm (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011).

8 *សូមមើល* ទិន្នន័យផលិតផលបង្គារនាំខែធ្នូ ឆ្នាំ2010 នៃសេវាកម្មនេសាទសមុទ្រ NOAA *ដែលអាចមាននៅក្នុងគេហទំព័រ*

http://www.st.nmfs.noaa.gov/st1/market_news/archives/index.html (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011)។

9 *See* NOAA Fisheries Service ខែឧសភា ឆ្នាំ2011 Shrimp Statistics, *ដែលអាចមាននៅក្នុងគេហទំព័រ*

http://www.st.nmfs.noaa.gov/st1/market_news/doc45.txt (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011)។

10 *Id.*

ផលិតផលបង្គារ (គ្រប់ប្រភេទ អត់ក្បាល រាប់ពាន់ផោន) [11]

| | Florida | Alabama | Mississippi | Louisiana | Texas | សរុប |
|---|---|---|---|---|---|---|
| ខែឧសភា ឆ្នាំ 2011 | 733.0 | 314.0 | 551.0 | 10,630.3 | 2,776.5 | 15,004.7 |
| ខែឧសភា ឆ្នាំ | 698.5 | 263.0 | 45.9 | 4,135.9 | 1,957.9 | 7,101.2 |
| ខែឧសភា ឆ្នាំ | 572.7 | 111.0 | 237.1 | 12,701.1 | 2,666.3 | 16,288.3 |
| ខែឧសភា ឆ្នាំ | 215.7 | 126.0 | 38.7 | 8,614.5 | 1,450.8 | 10,445.7 |
| ខែឧសភា ឆ្នាំ 2007 | 660.9 | 152.5 | 133.8 | 10,684.3 | 1,460.6 | 13,092.1 |
| | | | | | | |
| ខែមករា - | 2,357.7 | 1,372.0 | 994.2 | 14,086.8 | 8,684.7 | 27,495.5 |
| ខែមករា - | 2,617.9 | 2,363.0 | 362.6 | 6,628.1 | 6,930.9 | 18,902.4 |
| ខែមករា - | 2,464.9 | 1,718.0 | 706.5 | 17,385.7 | 7,596.7 | 29,871.8 |
| ខែមករា - | 1,979.3 | 1,442.0 | 320.0 | 12,507.4 | 3,572.7 | 19,821.4 |
| ខែមករា - | 2,032.0 | 791.5 | 328.1 | 14,244.7 | 5,485.9 | 22,882.2 |

ផលិតផលនេសាទត្រីសមុទ្របានកើនឡើងល្អប្រសើរ។ ឧទាហរណ៍ យោងតាម NOAA ខែតុលា ឆ្នាំ2010 រដូវនេសាទត្រីសមុទ្រ ឆ្នាំ2010 កាលពីឆ្នាំកន្លងទៅ និងកំឡុងពេលក្រោយមក ការបើកដែននេសាទត្រីសមុទ្រ គឺល្អបំផុតនៅខែតុលាពាក់ព័ន្ធទៅនឹងផលិតផលនេសាទចាប់តាំងពីឆ្នាំ1983។[12]

រដូវនេសាទត្រីសមុទ្រ ឆ្នាំ2011 គឺមិនដូចគ្នាទៅនឹងការចាប់ផ្តើមដ៏ប្រសើរមួយ។ ផលិផតផលនេសាទរហូតដល់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2011 គឺ 25.4% លើអត្រាជាមធ្យមក្នុងរយៈពេលប្រាំឆ្នាំ។[13]

11 *Id.*

12 NOAA ការព្យាករណ៍ពីការនេសាទត្រីសមុទ្រ Menhaden ដោយប្រើអួននៅតាមសមុទ្រអាត្លង់ទិចនិងតំបន់ឈូងសមុទ្រឆ្នាំ 2011 និងការពិនិត្យមើលឡើងវិញពីរដូវការនេសាទឆ្នាំ 2010 ខែមិនាឆ្នាំ 2011 *អាចចូលបានតាមរយៈគេហទំព័រ*http://www.st.nmfs.noaa.gov/st1/market_news/menhaden_forecast_2011.pdf (ចូលទស្សនាចុងក្រោយនៅខែ កក្កដា 5, 2011).

13 NOAA, "ស្ថានភាពផលិតផលនេសាទដោយប្រើអួននៅតំបន់ឈូងសមុទ្រ និងផលិតផលនេសាទត្រីនៅសមុទ្រអាត្លង់ទិចក្នុងរដូវនេសាទឆ្នាំ 2011" ថ្ងៃទី 5 ខែកក្កដា ឆ្នាំ 2011,
*អាចចូលបានតាមរយៈគេហទំព័រ*http://www.st.nmfs.noaa.gov/st1/market_news/doc77.txt (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 7 ខែឧសភា ឆ្នាំ2011).

3. <u>របាយការណ៍ពាក់ព័ន្ធទៅនឹងប្រភេទត្រីសមុទ្រ (Snapper)</u>

ស្ថាប័ន GCCF ថ្មីៗនេះបានស្នើអោយក្រុមហ៊ុនប្រេងប៊ីភី BP ឆ្លើយតបទៅនឹងចំណងជើងសារព័ត៌មានដែលបានផ្សាយរបាយការណ៍កត់សំគាល់ពីរបួសរបស់ត្រីនៅក្នុងតំបន់ឈូងសមុទ្រមកស្ថាប័ន GCCF។ [14] របួសរបស់ត្រីគ្មានអ្វីថ្មីទេ។ ពួកគេមិនបានរាយការណ៍ពីព័ត៌មាននៃតំបន់ឈូងសមុទ្រ Mexico និងស្ថានភាពទឹកនៅតាមទីតាំងភូមិសាស្ត្រផ្សេងៗគ្នានៅទូទាំងពិភពលោកជាញឹកញាប់ទេ។ ដោយផ្តោតទៅលើការនេសាទអតិផលនៅតាមតំបន់ឈូងសមុទ្រនៅពេលនេះ របាយការណ៍ពីស្នាមរបួសរបស់ត្រីត្រូវបានគេយកមកសិក្សាស្រាវជ្រាវយ៉ាងមត់ចត់ និងភ្លាមៗ។ មកទល់ពេលសព្វថ្ងៃនេះ គ្មានភស្តុតាងណាបានផុសចេញ ហើយផ្តល់យោបល់ថាចំនួនត្រីនៅក្នុងឈូងសមុទ្រមាន "ជំងឺ" ជំងឺមួយចំនួនដែលបានកើតឡើងដោយសារការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon ។ ដើមខែនេះ នាយករងនាយកដ្ឋានធនធានសមុទ្ររដ្ឋ Mississippi បានពន្យល់ថា:[15]

> 'ថ្មីៗនេះ យើងមើលមិនឃើញពីការកើតឡើងខុសប្រក្រតីណាមួយចំពោះប្រភេទត្រី' ទេ លោក Jewell មានប្រសាសន៍។
> 'ទិន្នន័យដែលមាន និងព័ត៌មានទាំងអស់បង្ហាញថា

ត្រីស្ទើតែទាំងអស់ ទោះជាមិនទាំងអស់ក៏ដោយ
ដែលបានពិនិត្យឃើញថាអាចមើលឃើញខ្លះៗពីលក្ខខណ្ឌខា
ងក្នុង ឬខាងក្រៅត្រូវបានកើតពីរ វីរុស បាតេរី
និងប៉ារ៉ាសិតដែលកើតឡើងក្នុងធម្មជាតិ។'

'យើងយល់ថាការពីបារម្មណ៍អំពីត្រីក្រហម snapper
ហើយយើងចង់ធានាជាសាធារណៈថាត្រីក្រហម snapper
មានសុវត្ថិភាព និងនាយកដ្ឋានធនធានសមុទ្រ DMR
កំពុងធ្វើការគ្រប់គ្រង
និងតេស្តមើលដើម្បីធានាពីសុវត្ថិភាពនេះ'

C. <u>កត្តាអនាគតកាលមិនត្រូវបានអនុញ្ញតដោយភស្តុតាងឡើយ</u>

សរុបសេចក្តីមក ភស្តុតាងជាច្រើនបង្ហាញអោយឃើញថា

ក្នុងក្របខណ្ឌនៃផ្នែកនីមួយៗនៃសេដ្ឋកិច្ចក្នុងតំបន់សមុទ្រដោយសារការធ្លាយប្រេង

សេចដ្ឋកិច្ចបានស្តារឡើងវិញ

ហើយគ្មានមូលដ្ឋានណាដើម្បីបន្តការទូទាត់ប្រាក់សំណងកត្តាអនាគតកាលចំពោះហានិភ័យនៃ

ការខូចខាតនាពេលអនាគត។ ដូច្នេះ ភាពសមស្របជាមួយ

14 ដូចគ្នានេះដែរ ស្ថាប័ន GCCF បានស្នើថា ក្រុមហ៊ុនប្រេងប៊ីភី BP ឆ្លើយតបទៅនឹងចំណាងជើងសារព័ត៌មាន ដែលពាក់ព័ន្ធទៅនឹងជម្រករបស់សត្វអណ្តើក Kemp's Ridley។

---

14 ដូចគ្នានេះដែរ ស្ថាប័ន GCCF បានស្នើថា ក្រុមហ៊ុនប្រេងប៊ីភី BP
ឆ្លើយតបទៅនឹងចំណាងជើងសារព័ត៌មាន ដែលពាក់ព័ន្ធទៅនឹងជម្រករបស់សត្វអណ្តើក
Kemp's Ridley។ អណ្តើក Kemp's Ridley
ត្រូវបានគេសិក្សាស្រាវជ្រាវយ៉ាងទូលំទូលាយដែលជាផ្នែកមួយនៃការវាយតម្លៃសហប្រតិប
ត្តិការណ៍ NRDA ដែលកំពុងត្រូវបានអនុវត្តដោយក្រុមប្រឹក្សាភិបាល NRD

និងក្រុមហ៊ុនប្រេងប៊ីភី BP។ ចំណាងជើងដែលដកស្រង់ចេញពីដោយស្ថាប័ន GCCF មិនបានសំគាល់អោយភស្តុតាងណាមួយនៃបញ្ហាទាក់ទងនឹងការធ្លាយជាមួយនឹងអណ្តើក Kemp's Ridley។

ផ្ទុយមកវិញ ចំណាងជើងបានកត់សំគាល់ថាជម្រករបស់អណ្តើត Kemp's Ridley នៅត្បាមម្ខាត់ឆ្នេររដ្ឋ Texas ដែលជាជម្រកមួយក្នុងចំណោមដែនជម្រកដ៏សំខាន់ គឺលើកម្រិតនៃឆ្នាំ 2009។

15 *Biloxi Sun Herald* "នាយកដ្ឋានធនធានសមុទ្រនិយាយថាជម្រកត្រីក្រហម Snapper គឺមានសុវត្ថិភាព" ថ្ងៃទី 14 ខែមិថុនា ឆ្នាំ 2011។

ការទូទាត់ប្រាក់សំណង

ជាមួយនឹងការលើកលែងនៃការទូទាត់ប្រាក់សំណងមានកំណត់មួយចំពោះអ្នកទាមទារប្រាក់សំណាង ដែលនេសាទអយស្ទ័រពីដែននេសាទ ត្រូវបានបំផ្លាញដោយសារប្រេងពីអណ្តូងប្រេង Macondo (ហើយ យើងមិនយល់ពីឧទាហរណ៍នៃការធ្លាយទាំងនេះ) និងជាអ្នកដែលគ្មានប្រភពអាចរកចំណូលបានផ្សេងទៀត។ អ្នកទាមទារប្រាក់សំណាងខ្លះ ដែលស្ថិតក្នុងស្ថានភាពនេះ ទោះជាមានទិន្នន័យសេដ្ឋកិច្ចក៏ដោយ និងមានហានិភ័យនៃការបាត់បង់នាពេលអនាគតខ្ពស់ណាស់ ដើម្បីឈានទៅដល់ការទូទាត់ចុងក្រោយ គឺមានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារប្រាក់សំណាងបណ្តោះអាសន្ន និងស្វែងរកការទូទាត់ប្រាក់សំណាងទៅលើការខាតបង់នាពេលកន្លងមកដោយគ្មានចុះហត្ថលេខាឈប់ទាមទារប្រាក់សំណាង។

ក្រៅពីនេះ

ការកែសម្រួលណាមួយត្រូវតែម្រូវអោយមានដោយមានការពាក់ព័ន្ធទៅនឹងពាក្យសុំរបស់ស្ថាប័ន GCCF ក្នុងការលើកកំពស់កត្តាអនាគតកាល 300% របស់ខ្លួនសម្រាប់អ្នកនេសាទអយស្ទ័រ និងអ្នកកែច្នៃ។ ក្រុមហ៊ុនប្រេងប៊ីភី BP យល់ឃើញថាពេលថ្មីៗនេះ ស្ថាប័ន GCCF

កំពុងទូទាត់ប្រាក់សំណងទៅអោយអ្នកនេសាទអយស្ទ័រ និងអ្នកកែច្នៃនៅតំបន់ឈូងសមុទ្រ ដែលអាចបង្ហាញថានៅឆ្នាំ2010 មានការបាត់បង់កត្តាអនាគតកាល 300%។ វាមិនសមស្របជាមួយនឹងវិធីសាស្រ្តផ្ទាល់របស់ស្ថាប័ន GCCF និងគ្មានមូលដ្ឋានជាក់ស្តែង។

វិធីសាស្រ្តចុងក្រោយរបស់ស្ថាប័ន GCCF ផ្តល់កត្តាអនាគតកាលជាចំហ (300% នៃការបាត់បង់ឆ្នាំ 2010) ទៅអោយអ្នកនេសាទអយស្ទ័រ និងអ្នកកែច្នៃ ដែលនេសាទ/ទាញយកធនធានពីឡូចិញ្ចឹមអយស្ទ័រដែលត្រូវបានបំផ្លាញដោយប្រេង ប្រសិនជាមាន ឬការប្រែប្រួលចរន្តទឹកសាបនៅរដ្ឋ Louisiana តាមរយៈទ្រឹស្តីគឺការបង្កើតអោយមានដែនសមុទ្រទាំងនេះឡើងវិញនឹងចំណាយរយៈពេលយូរ ។ "អ្នកឯកទេសព្យាករណ៍ថាបុគ្គល ឬអាជីវកម្មដែលបានបានជាប់គាំងនៅក្នុងការនេសាទ និងកែឆ្នៃអយស្ទ័រ ដែលត្រូវបានបំផ្លាញដោយសារការធ្លាយប្រេង ឬដោយសារការប្រែប្រួលចរន្តទឹកសាបនៅក្នុងតំបន់ឈូងសមុទ្រដែលនាំអោយមានប្រតិកម្មនៃការធ្លាយប្រេង នឹងត្រូវការរយៈពេលស្តារឡើងវិញក្នុងរយៈពេលយូរជាង ដែលខុសពីអ្នកទាមទារប្រាក់សំណងផ្សេងទៀតធ្លាប់ឆ្លងកាត់ ដោយកម្រិតនៃការស្តារឡើងវិញបន្តិចម្តងៗពុំដូចគ្នាទេ។ ដូច្នេះហើយ

ការផ្តល់ជូនការទូទាត់ចុងក្រោយសម្រាប់អ្នកទាមទារប្រាក់សំណងទាំងនោះនឹងសមមូលទៅនឹងចំនួនបួនដងនៃការខាតបង់ដូចបានបំពេញក្នុងឯកសារជាក់ស្តែងឆ្នាំ2010។"

វិធីសាស្ត្រចុងក្រោយ 5។(ការលុបចោល)។

ចំពោះការយល់ដឹងរបស់យើង សព្វថ្ងៃនេះ ស្ថាប័ន GCCF មិនបានទទួលឯកសារទាក់ទងនឹងឡូចិញ៉ឹមអយស្ទ័រណាមួយដែលបានបំផ្លាញដោយសារការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon។ ពីភស្តុតាងផ្ទុយនោះ គ្មានអ្នកនេសាទអយស្ទ័រ ឬអ្នកកែច្នៃណាមានសិទ្ធិគ្រប់គ្រាន់សម្រាប់កត្តាអនាគតកាលជាចំហរទេ។

ផ្អែកតាមវិធីសាស្រ្តចុងក្រោយរបស់ស្ថាប័ន GCCF

ថ្វីបើគ្មានប្រេងហៀរចូលនៅក្នុងដែននេសាទក៍ដោយ

ក៏កត្តាអនាគតកាលជាចំហអាចទទួលបានដែរ

ប្រសិនបើដែនសាទត្រូវបានបំផ្លាញដោយសារការថយចុះនៃបរិមាណជាតិប្រៃ

ដែលបណ្តាលមកពីភាពប្រែប្រួលចរន្តទឹកសាបនៅឆ្នាំ 2010 រដ្ឋ Louisiana

ចូលទៅក្នុងតំបន់ឈូងសមុទ្រឆ្នាំ2010។ ក្រុមហ៊ុនប្រេងប៊ីភី BP

មិនទទួលខុសត្រូវចំពោះសកម្មភាពរបស់រដ្ឋ Louisiana ដូច្នេះហើយ ស្ថាប័ន GCCF

មិនអាចទូទាត់សងទៅអោយអ្នកទាមទារប្រាក់សំណង

មិនថាកម្រិតណាមួយទេ ពុំទាន់និយាយដល់កត្តាអនាគតកាលជាចំហ
សម្រាប់ការខូចខាតដែលបណ្តាលមកពីការប្រែប្រួលចរន្តទឹកសាប។

ទោះបីជាក្រុមហ៊ុនប្រេងប៊ីភី BP ទទួលខុសត្រូវចំពោះសកម្មភាពរបស់រដ្ឋ Louisiana

ហើយវាសមស្របក្នុងការផ្តល់ជូនកត្តាអនាគតកាលជាចំហនោះទៅអោយអ្នកនេសាទ

និងអ្នកកែច្នៃទាំងនោះ ដែលទាញយកផលពីឡូចិញ្ចឹមអយស្ទ័រ

ដែលត្រូវបានបំផ្លាញដោយសារភាពប្រែប្រួលចរន្តទឹកសាបរដ្ឋ Louisiana

កត្តាអនាគតកាលជាចំហានោះនឹងអាចផ្តល់ជូនបានសម្រាប់អ្នកទាមទារប្រាក់សំណងទាំងនោះ

ដែលអាចបង្ហាញភស្តុតាងពីការបំផ្លាញដែលពាក់ព័ន្ធទៅនឹងការប្រែប្រួលចរន្តទឹកតែប៉ុណ្ណោះ។ ប៉ុន្តែ យើងយល់ថា ស្ថាប័ន GCCF នឹងអនុវត្តនូវកត្តាអនាគតកាលដែលបានជ្រុញនោះចំពោះរាល់ពាក្យបណ្តឹងទាមទារសំណងទាំងអស់ដែលផ្ញើមកដោយអ្នកនេសាទអយស្ទ័រ និងអ្នកកែច្នៃនៅគ្រប់កន្លែងក្នុងតំបន់ឈូងសមុទ្រ ថ្វីបើជាទីតាំងរបស់ពួកគេក៏ដោយ។ ដូច្នេះ ស្ថាប័ន GCCF នឹងទូទាត់ចំណាយកត្តាអនាគតកាល 300% ទៅអោយអ្នកនេសាទអយស្ទ័រនៅរដ្ឋ Florida និង Alabama ទោះបីជាដែននេសាទរបស់ពួកគេមិនបានទទួលរងផលប៉ះពាល់ដោយសារភាពប្រែប្រួលចរន្តទឹកសាបរដ្ឋ Louisiana។ ការទូទាត់ទាំងនេះមិនសមស្របតាមវិធីសាស្ត្រផ្ទាល់របស់ស្ថាប័ន GCCF។

កាន់តែខិតទៅដល់ចំនុចនេះ ពេលថ្មីៗនេះ កងទាហានវិស្វកម្មសហរដ្ឋអាមេរិកបានធ្វើការសម្រេចចិត្តដោយពិបាកមួយដើម្បីបើកទំនប់បង្ហៀរយ៉ាងតិចចំនួនពីរនៅក្នុងរដ្ឋ Louisiana ដើម្បីព្យាយាកាត់បន្ថយទឹកជំនន់តាមបណ្តោយទន្លេ Mississippi ផ្នែកខាងក្រោម។

ត្រូវបានព្យាករណ៍ថាការកាត់បន្ថយជាតិប្រៃដោយសារបរិមាណចរន្តទឹកសាបមួយភាគធំទៅតាមដៃសមុទ្រ និងឆ្នេរសមុទ្រ ផ្សេងទៀតដែលអាចបង្កអោយមានផលអាក្រក់ដល់ចំនួនអយស្ទ័រ។

ស្ថប័ន GCCF

នឹងត្រូវការវាយតម្លៃពាក្យបណ្តឹងទាមទារប្រាក់សំណងទៅលើការខូចខាតឡូចិញ្ចឹមអយស្ទ័រដោយមានការប្រុងប្រយ័ត្ន ប្រសិនបើដូច្នេះ

ការហៀរចេញនេះមិនមានការពាក់ព័ន្ធទាំងស្រុងជាមួយនឹងក្រុមប្រេងប៊ីភី BP

ឬការធ្លាយប្រេងនៅតំបន់ទឹកជ្រៅ Deepwater Horizon ទេ

ហើយក៏មិនមានការទូទាត់សងដោយស្ថាប័ន GCCF ដែរ។

II.

មានការកែតម្រូវជាច្រើនចំពោះវិធីសាស្រ្តដោះស្រាយពាក្យបណ្តឹងទាមទារប្រាក់សំណងរបស់ស្ថាប័ន GCCF

<u>ទាមទារអោយមានការទូទាត់ប្រាក់សំណងទៅលើពាក្យបណ្តឹងទាមទារសំណងអោយបានសមស្របតាមក្របខណ្ឌនៃច្បាប់ OPA</u>

A. ច្បាប់ OPA បានអោយនិយមន័យនៃក្របខណ្ឌពាក្យបណ្តឹងទាមទារប្រាក់សំណង <u>នៃការខាតបង់សេដ្ឋកិច្ចដែលស្ថាប័ន GCCF អាចទូទាត់ប្រាក់សំណងជូន និងចំនួននៃការទូទាត់ប្រាក់សំណងទាំងនោះ</u>

នៅចុងខែមេសា ឆ្នាំ2010

ការិយាល័យឆ្មាំឆ្នេរសមុទ្រសហរដ្ឋអាមេរិកបានជ្រើសរើសក្រុមហ៊ុនប្រេងប៊ីភី BP រួមជាមួយនឹង Transocean Anadarko និង MOEX ជាដៃគូរទទួលខុសត្រូវដោយយោងតាមច្បាប់ OPA។ ច្បាប់ OPA ទាមទារអោយដៃគូរទទួលខុសត្រូវបង្កើតនូវពិធីការក្នុងការទូទាត់ប្រាក់សំណង និងទទួលពាក្យបណ្តឹងទាមទារសំណង។ *សូមពិនិត្យមើលជារួម* 33 U.S.C. § 2714. ក្នុងរយះពេលមានការធ្លាយប្រេង ក្រុមហ៊ុនប្រេងប៊ីភី BP បានបង្កើតដំណើរការពាក្យបណ្តឹងទាមទារប្រាក់សំណងនៅកម្រិតខ្ពស់ជាង និងអោយមានភាពច្បាស់លាស់ជាង ដែលវាស្របទៅតាមតម្រូវការនិតិក្រមច្បាប់ OPA។ ក្រោយថ្ងៃប្រជុំនៅថ្ងៃទី 16 ខែមិថុនា ឆ្នាំ 2010 ក្រុមហ៊ុនប្រេងប៊ីភី BP និងសេតវិមានបានយល់ព្រមថា ក្រុមហ៊ុនប្រេងប៊ីភី BP

នឹងផ្ទេរទំនួលខុសត្រូវក្នុងការគ្រប់គ្រងការសម្របសម្រួលពាក្យបណ្តឹងទាមទារប្រាក់សំណងបុគ្គល និងអាជីវកម្មយោងតាមច្បាប់ OPA របស់ខ្លួន ទៅអោយស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារប្រាក់សំណងដែលជាដៃគូរទីបី (ដែលមានឈ្មោះខាងក្រោមជា ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារប្រាក់សំណងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ) ដែលបានដឹកនាំការងារដោយលោក Kenneth R. Feinberg។ ក្រៅពីពាក្យបណ្តឹងទាមទារប្រាក់សំណងដែលស្របតាមច្បាប់ OPA ក្រុមហ៊ុនប្រេងប៊ីភី BP ក៏បានយល់ព្រមអោយស្ថាប័ន GCCF ដែលគ្រប់គ្រងពាក្យបណ្តឹងទាមទារប្រាក់សំណងសម្រាប់របួសរាងកាយ និងមរណៈភាពផងដែរ។

ដោយមានការយល់ព្រមក្នុងផ្ទេរទំនួលខុសត្រូវ ស្ថាប័ន GCCFកំពុងបំពេញកាតព្វកិច្ចនៃច្បាប់ OPA របស់ក្រុមហ៊ុនប្រេងប៊ីភី BP គឺស្ថាប័ន GCCF មានសិទ្ធិទូទាត់ប្រាក់សំណងទៅអោយពាក្យបណ្តឹងទាមទារប្រាក់សំណងបានទូលំទូលាយបានតែក្នុង ក្របខណ្ឌនៃការផ្ទេរសិទ្ធិដែលបានធ្វើឡើងតែប៉ុណ្ណោះ។ ការផ្ទេរសិទ្ធិនោះ

ជាមួយការលើកលែងករណីពាក្យបណ្ដឹងទាមទារប្រាក់សំណងសម្រាប់របួសរាងកាយ និងមរណៈភាព មិនបានអនុញ្ញាតអោយស្ថាប័ន GCCF ធ្វើការទូទាត់ទៅអោយពាក្យបណ្ដឹងទាមទារប្រាក់សំណងក្រៅក្របខណ្ឌនៃច្បាប់ OPA ឡើយ។ តាមកិច្ចសន្យាដែលក្រុមហ៊ុនប្រេងប៊ីភី BP បានអនុញ្ញាតអោយស្ថាប័ន GCCF គ្រប់គ្រងដំណើរការពាក្យបណ្ដឹងទាមទារប្រាក់សំណងស្របតាមច្បាប់ OPA របស់ក្រុមហ៊ុនប្រេងប៊ីភី BP គឺស្ថាប័ន GCCF បានយល់ព្រមយ៉ាងរហ័សថា"លោក Feinberg Rozen នឹងអនុវត្តតាមច្បាប់ OPA ដូចជាគេបានប្រតិបត្តិ និងគ្រប់គ្រងស្ថាប័ន GCCF អញ្ចឹង។" កិច្ចសន្យារវាងក្រុមហ៊ុនប្រេងប៊ីភី BP និងលោក Feinberg Rozen § 1(b).

ស្ថាប័ន GCCF បានទទួលស្គាល់ខ្លួនឯងថា តួនាទីរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ដោយយោងតាមច្បាប់ OPA ដើម្បីរក្សាដំណើរការពាក្យបណ្ដឹងទាមទារប្រាក់សំណង: "លោក Feinberg និង ស្ថាប័ន GCCF កំពុងដើរតួនាទីសម្រាប់ និងតំណាងអោយក្រុមហ៊ុន BP Exploration & Production ក្នុងការបំពេញកាតព្វកិច្ចលក្ខន្តិកៈរបស់ក្រុមហ៊ុនប្រេងប៊ីភី BP 'ជាដៃគូរទទួលខុសត្រូវ'

យោងតាមច្បាប់កង្វក់នៃប្រេងឆ្នាំ 1990។"[16] សិទ្ធិរបស់ស្ថាប័ន GCCF

ទៅលើពាក្យបណ្ដឹងទាមទារសំណងខាងសេដ្ឋកិច្ចដែលមិនអោយហួសពីកម្រិតក្របខណ្ឌនៃ

ច្បាប់ OPA ដែលត្រូវបានបញ្ជាក់ឡើងវិញរួចហើយ ទៅតាមនិតិក្រមរបស់ស្ថាប័ន GCCF

សម្រាប់ពាក្យបណ្ដឹងចុងក្រោយ និងបណ្ដោះអាសន្ន ("និតិក្រម")

ដូចបានចែងក្នុងប្រភេទនៃពាក្យបណ្ដឹងទាមទារប្រាក់សំណងខាងសេដ្ឋកិច្ច

រងរបួស/មរណៈភាព ជាក្រុម ដែលអ្នកទាមទារប្រាក់សំណងបុគ្គល

ឬអាជីវកម្មអាចដាក់ពាក្យបណ្ដឹងមកស្ថាប័ន GCCF

និតិក្រមបានកំណត់ដោយខ្លួនឯងចំពោះការចែងនៅក្នុងច្បាប់ OPA:

តម្លៃចំណាយក្នុងបោសសំអាត និងយកចេញ ការខូចខាតទៅលើការខូចខាត

ឬការបំផ្លិចបំផ្លាញ

ទ្រព្យសម្បត្តិ

ការខូចខាតសម្រាប់ការបាត់បង់ការប្រើប្រាស់ធនធានធម្មជាតិសម្រាប់ចិញ្ចឹមជីវិត

និងការខាតបង់ប្រាក់ចំណេញ និងប្រាក់ចំណូលដែលរកបាន។ និតិក្រម GCCF § II.A-D.

ពីព្រោះវាគ្រាន់តែជាការផ្ដល់សិទ្ធិក្នុងការបំពេញកាតព្វកិច្ចលក្ខន្តកៈរបស់ក្រុមហ៊ុនប្រេង

ប៊ីភី BP យោងតាមច្បាប់ OPA ស្ថាប័ន GCCF

ត្រូវតែទូទាត់ប្រាក់សំណងទៅអោយពាក្យបណ្តឹងទាមទារប្រាក់សំណងទាំងឡាយណាដែលពេ

ញលក្ខណៈទទួលបានការទូទាត់សងដោយយោងតាមច្បាប់ OPA

និងត្រូវតែបដិសេធចំពោះពាក្យបណ្តឹងទាមទារប្រាក់សំណងទាំងឡាយណាដែលមិនមានលក្ខ

ណៈសមស្របនោះ។

កន្លែងដែលពាក្យបណ្តឹងមានលក្ខណៈទទួលបានសម្រាប់ការទូទាត់សងប្រាក់សំណង

ការខូចខាតត្រូវបានកំណត់ក្នុងក្របខណ្ឌនៃការស្តារឡើងវិញទាំងនោះដោយយោងតាមច្បាប់

OPA។ ក្នុងនាមនៃការផ្ទេរសិទ្ធិរបស់ក្រុមហ៊ុនប្រេងប៊ីភី BPទៅអោយស្ថាប័ន GCCF

និងមិនមែនក្រុមហ៊ុនប្រេងប៊ីភី BP គឺស្ថាប័ន GCCF ទទួលខុសត្រូវក្នុងការវាយតម្លៃ

និងធ្វើការសម្រេចទៅលើពាក្យបណ្តឹងទាមទារប្រាក់សំណងបុគ្គល។

ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃ និងការសម្រេចចិត្តទាំងនេះត្រូវតែអនុវត្ត

និងធ្វើមិនអោយហួសពីក្របខណ្ឌច្បាប់ OPA។

ដូចបានពណ៌នាខាងក្រោម ស្ថាប័ន GCCF

បានអនុវត្តហួសពីសិទ្ធិរបស់ខ្លួនមានសម្រាប់ការងារពាក់ព័ន្ធណាមួយ ក្នុងករណីខ្លះ

ដែលមិនអនុវត្តតាមតម្រូវការសហេតុកម្មរបស់ច្បាប់ OPA

និងការគណនាការខូចខាតតាមមធ្យោបាយដែលនាំអោយមានការការទូទាត់សងប្រាក់សំណង

ច្រើនហួស។

B. <u>សហេតុកម្មគឺជាតម្រូវការមូលដ្ឋានមួយរបស់ច្បាប់ OPA</u>

ស្ថាប័ន GCCF បានលើកឡើងនូវសម្មតកម្មជាច្រើន

ដែលជាផ្នែកមួយនៃកម្មវិធីពាក្យបណ្តឹងមិនបន្ទាន់

ដែលមិនស្របទៅតាមតម្រូវការសហេតុកម្មរបស់ច្បាប់ OPA។ <u>ទីមួយ</u>

ប្រសិនបើអ្នកទាមទារប្រាក់សំណងបានទទួលការទូទាត់ប្រាក់សំណងដោយយោងតាមកម្មវិធី

ទូទាត់ប្រាក់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់របស់ស្ថាប័នGCCF

ដែលបានរៀបចំដើម្បីផ្តល់ការទូទាត់ប្រាក់សំណងបន្ទាន់បណ្តោះអាសន្នភ្លាមៗជាមួយនឹងឯក

សារដែលបានកំណត់ ស្ថាប័ន GCCF

សន្មតពីគោលបំណងរបស់ពាក្យបណ្តឹងទាមទារសំណងបណ្តោះអាសន្ន និងចុងក្រោយ

ដែលអ្នកទាមទារប្រាក់សំណងបានទទួលរងនូវការខាតបង់ពីខែឧសភា ដល់ខែធ្នូ ឆ្នាំ2010 គឺ។

---

16 Gulf Coast Claims Facility home page, *អាចចូលបានតាមរយៈគេហទំព័រ* http://www.gulfcoastclaimsfacility.com/index (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011).

បណ្ដាលមកពីការផ្លាយប្រេង ក្រៅពីការមិនបានអនុវត្តតាមច្បាប់ OPA

ភាពខ្វះចន្លោះនៃតម្រូវការសហេតុកម្មសម្រាប់អ្នកទទួលបានការទូទាត់ជាមុនសម្រាប់តម្រូវការ

បន្ទាន់គឺផ្ដល់ជូនមិនបានសមស្រប

ដែលកម្មវិធីទូទាត់ប្រាក់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់មិនបានស្របតាមការវាយតម្លៃ

ពេញលេញនៃសហេតុកម្ម ដូចបានរៀបចំ។ ក្រៅពីនេះ បើនិយាយពី

ការទូទាត់ប្រាក់សំណងបណ្ដោះអាសន្ន និងភ្លាមៗទៅអោយអ្នកទាមទារប្រាក់សំណង

កម្មិធីទូទាត់ប្រាក់សំណងជាមុនសម្រាប់តម្រូវការបន្ទាន់មានកំហុសក្នុងការទូទាត់សងប្រាក់សំ

ណាង ពេលធ្វើការវិភាគពី សហេតុកម្មអោយបានហ្មត់ចត់កំឡុងពេលដំណាក់កាលមិនបន្ទាន់។

ការសន្មតជាមុននេះបានឈានទៅដល់ការទូទាត់ប្រាក់សំណងទៅអោយអ្នកទាមទារប្រាក់សំ

ណាងច្រើនដោយគ្មានការសម្រេចថា ពួកគេបានធ្វើតាមតម្រូវការសហេតុកម្មរបស់ច្បាប់ OPA។

ឧទាហរណ៍ ស្ថាប័ន GCCF បានទូទាត់ចំណាយទៅអោយរោងចក្រ

ផលិតសម្ភារៈដំបូលផ្ទះ ក្រុមជីកដី/ដឹកជញ្ជូនដី ក្រុមហ៊ុនសំណង់នៅក្នុងរដ្ឋ Florida

Keys ក្រុមហ៊ុនជួសជុលកញ្ចក់ និងហាងលក់សម្ភារៈរៀបចំសួនច្បារ។

<u>ទីពីរ</u> និងស្រដៀងគ្នានេះដែរ ស្ថាប័ន GCCF

សន្មតថាករណីធ្លាយប្រេងត្រូវទទួលខុសត្រូវចំពោះរាល់ការខាតបង់ដែលកើតឡើងចំពោះអ្នកទាមទារប្រាក់សំណង ដែលជាអ្នក (i) មានទីតាំងភូមិសាស្ត្រនៅក្នុងតំបន់លេខកូដហ្សីបឆ្នេរសមុទ្រ និង (ii)អ្នកនេសាទត្រី ធ្វើការក្នុងសណ្ឋាគារ ភោជនីដ្ឋាន បារ និងឧស្សាហកម្មជួលបន្ទប់សម្រាប់ពេលលំហែរកាយរដូវមកាល។ ម្តងទៀត ការសន្មតទាំងនេះមិនបានស្របទៅនឹងតម្រូវការសហេតុកម្មរបស់ច្បាប់ OPA។ អ្នកទាមទារប្រាក់សំណងបុគ្គល និងអាជីវកម្មទទួលរងការខាតបង់សេដ្ឋកិច្ចដោយសារមូលហេតុច្រើន។ គេមិនអាចសន្មតថារាល់ការខាតបង់ដែលកើតឡើងចំពោះប្រភេទអាជីវកម្មមានច្រើន និងនយោជិកសុទ្ធតែបណ្តាលមកពីការធ្លាយប្រេងនោះឡើយ។ នេះគឺជាបង្ហាញដោយព្រឹត្តិការណ៍មួយ ដែលអ្នកទាមទារប្រាក់សំណងជាច្រើន បានទទួលការទូទាត់ប្រាក់សំណង នៅតែទទួលរង ដោយសារការខាតបង់ពាក់ព័ន្ធទៅនឹងនៅឆ្នាំ 2009 មុនការធ្លាយប្រេង។ ការសន្មតរបស់ស្ថាប័ន GCCF មិនអាចបង្ហាញពីទីតាំងភូមិសាស្ត្រណាមួយទេ

ប៉ុន្តែអាចក្លាយទៅជាការមួយមិនអាចបកស្រាយបានចំពោះការទទួលបានការទូទាត់ប្រាក់សំណងពីការធ្លាយប្រេង ។ ឧទាហរណ៍ ទោះជាការធ្លាយប្រេងមិនមានការប៉ះពាល់ទៅដល់មាត់ឆ្នេរសមុទ្ររដ្ឋ Texas (លើកលែងតែគ្រាប់ជ័រអណ្តែត មួយចំនួនតូចនៅក្នុងទីតាំង) ស្ថាប័ន GCCF សន្មតថា ការខាតបង់ទាំងអស់បានកើតឡើងដោយអាជីវកម្មនេសាទ សណ្ឋាគារ ភោជនីយដ្ឋាន បារ កន្លែងជួសស្នាក់នៅ និងនយោជិករបស់ពួកគេនៅជុំវិញរដ្ឋតំបន់លេខកូដប្បៃបឆ្នេរសមុទ្រTexas ដែលទទួលឥទ្ធិពលពីការធ្លាយប្រេង។ កាសន្មតដូចគ្នាត្រូវបានអនុវត្តសម្រាប់អ្នកទាមទារប្រាក់សំណងនៅ Florida Keys និង

ប្រជុំកោះ Florida ក៏ដោយ ទោះជាប្រេងហៀរមកពីតំបន់ទឹកជ្រៅ Deepwater Horizon ដែលមិនដែលហៀរមកក្បែរ Keys ឬ

ប្រជុំកោះ Florida ក៏ដោយ។

<u>ទីបី</u>

សម្រាប់អ្នកទាមទារប្រាក់សំណងចំនុះអោយប្រភេទអាជីវកម្មចំរុះដែលមានទីតាំងនៅក្នុងតំប

ន់ក្រៅពីតំបន់លេខកូដហ្សីបឆ្នេរសមុទ្រចំងាយ 100 ម៉ាយ ពីតំបន់ឆ្នេរជាប់ឈូងសមុទ្រ

ស្ថាប័ន GCCF សន្មតយ៉ាងសមញ្ញថា

ការខាតបង់ដែលអះអាងរបស់អ្នកទាមទារសំណងត្រូវបានទទួលរងឥទ្ធិពលពីការធ្លាយប្រេ

ង

ក្នុងករណីមានការធ្លាក់ចុះផលទុនដែលបានអះអាងរបស់អ្នកទាមទារសំណងនៅខែឧសភា-

ធ្នូ ឆ្នាំ2010 ធៀបទៅនឹងខែឧសភា-ធ្នូ ឆ្នាំ 2009

គឺប្រសើរជាងការធ្លាក់ចុះផលទុនរបស់អ្នកទាមទារប្រាក់សំណងនៅខែមករា-មេសា ឆ្នាំ2010

បើធៀបទៅនឹងមករា-មេសា ឆ្នាំ2009។

ការសន្មតគ្មានហេតុផលនេះបាននាំអោយឈានទៅដល់ការទូទាត់ប្រាក់សំណងទៅអោយអ្នក

ទាមទារប្រាក់សំណងនៅឆ្ងាយ ពីតំបន់ឆ្នេរសមុទ្រ និងកន្លែងមានការធ្លាយប្រេង។ ឧទាហរណ៍

ផ្អែកតាមការសន្មតនេះ ស្ថាប័ន GCCF បានទូទាត់ប្រាក់សំណងទៅអោយសណ្ឋាគារជាច្រើននៅក្នុង Baton Rouge រដ្ឋ Louisiana ដែលសណ្ឋាគារទាំងអស់នោះមានទីតាំងឆ្ងាយពីតំបន់ឈូងសមុទ្រ Mexico។

ការប្រើប្រាស់ការសន្មតខាងលើជំនួសអោយការសម្រេចពីសហេតុកម្មជាក់ស្តែងគឺមិនបានអនុវត្តស្របតាមច្បាប់ OPA និងនិតិក្រមផ្ទាល់ខ្លួនរបស់ស្ថាប័ន GCCF ទេ។ សហេតុកម្មគឺជាតម្រូវការមូលដ្ឋានរបស់ច្បាប់ OPA។ យោងតាមច្បាប់ OPA ការខាតបង់ប្រាក់ចំណូល ឬប្រាក់ចំណេញដែលបានអះអាងគឺត្រូវបានទូទាត់សង ប្រសិនបើ និងថ្វីបើវាកើតឡើង "ដោយសារគ្រោះមហន្តរាយ ការបំផ្លេចបំផ្លាញ ឬការបាត់បង់អចលទ្រព្យ ទ្រព្យសម្បត្តិបុគ្គល ឬធនធានធម្មជាតិ" និងការខាតបង់ "បណ្តាលមកពី" ការធ្លាយប្រេង។ 33 U.S.C. §§ 2702(a), (b)(2)(E); *សូមមើល* មជ្ឈមណ្ឌលកង្វក់ជាតិនៃការិយាល័យឆ្មាំតំបន់ឆ្នេរសមុទ្រ លេខពាក្យបណ្តឹងទាមទារប្រាក់សំណង N10036-0009 (បានបដិសេធ ថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2010 បានពិចារណាឡើងវិញ នៅថ្ងៃទី15 ខែមីនា ឆ្នាំ2011) (ពាក្យបណ្តឹងដែលបដិសេធនៅទីកន្លែងដែលអ្នកទាមទារសំណងគ្មានភស្តុតាងបង្ហាញពីការខា

តបង់ដែលបានអះអាងដោយសារគ្រោះមហន្តរាយ ការបំផ្លេចបំផ្លាញ ឬបាត់បង់ទ្រព្យសម្បត្តិ

ឬធនធានធម្មជាតិ) លេខពាក្យ

មជ្ឈមណ្ឌលកង្វក់ជាតិនៃការិយាល័យឆ្មាំតំបន់ឆ្នេរសមុទ្រ

លេខពាក្យបណ្តឹងទាមទារប្រាក់សំណង N10036-0009 (បានបដិសេធ ថ្ងៃទី 12 ខែវិច្ឆកា ឆ្នាំ

2010) ពាក្យបណ្តឹងដែលបដិសេធនៅទីកន្លែងដែល NPFC មិន

"អាចបង្កើតអោយមានការខាតបង់ប្រាក់ចំណូល [ដែលបានអះអាង]

[គឺ]ជាផលវិបាកនៃការធ្លាយប្រេង").

ការទទួលស្គាល់ពីសហេតុកម្មគឺជាកត្តាចាំបាច់របស់ពាក្យបណ្តឹងស្របតាមច្បាប់ OPA

និតិក្រមរបស់ស្ថាប័ន GCCF ផ្តល់ជូន: "ស្ថាប័ន GCCF នឹងទូទាត់តែការខូចខាត

ឬផលអាក្រក់ដែលប្រហែលជាបណ្តាលមកពីការធ្លាយប្រេង។

ការសម្រេចពីសហេតុកម្មនៃពាក្យបណ្តឹងទាមទារប្រាក់សំណងស្របតាមច្បាប់ OPA

របស់ស្ថាប័ន GCCF នឹង

ត្រូវបានណែនាំដោយច្បាប់ OPA និងច្បាប់សហព័ន្ធដែលបកប្រែដោយ OPA។″ និតិក្រម II.G. វិធីសាស្រ្តចុងក្រោយរបស់ស្ថាប័ន GCCF បានលើកឡើងស្រដៀងគ្នានេះដែរ: "ស្ថាប័ន GCCF នឹងវាយតម្លៃពាក្យបណ្តឹងទាមទារប្រាក់សំណងនីមួយៗដើម្បីសម្រេចថាតើការខាតបង់បណ្តាលមកពីការធ្លាយប្រេងឬអត់។

អ្នកទាមទារប្រាក់សំណងម្នាក់ៗនឹងឈរនៅលើសិទ្ធិទទួលបានការដោះស្រាយទៅតាមបញ្ហាបុគ្គលផ្ទាល់ខ្លួនរបស់គេ ក្នុងករណីខ្លះ ត្រូវតែមានការធ្វើអត្តសញ្ញាណដូចជាការតភ្ជាប់ជាក់ស្តែងរវាងកាខាតបង់ និងករណីធ្លាយប្រេង។ ភស្តុតាងដែលកើតឡើងដោយសារការតភ្ជាប់នេះត្រូវតម្រូវអោយមាន។ ″ វិធីសាស្រ្តចុងក្រោយ 2។

ការសន្មតបានយល់ព្រមដោយស្ថាប័ន GCCF នាំអោយមានការទូទាត់ប្រាក់សំណងទៅអោយពាក្យបណ្តឹងទាមទារប្រាក់សំណងដែលមានលក្ខណ:ភូមិសាស្រ្ត និងសេដ្ឋកិច្ចនៅឆ្ងាយ ដែលពុំមានលក្ខណ:ទទួលបានការទូទាត់សងសំណងដោយយោងតាមច្បាប់ OPA។

1. <u>អ្នកទាមទារប្រាក់សំណងមានទីតាំងភូមិសាស្រ្តឆ្ងាយ</u>

ស្ថាប័ន GCCF បានទូទាត់ប្រាក់សំណងទៅអោយអ្នកទាមទារប្រាក់សំណងជាច្រើន ដែលមានទីតាំងភូមិសាស្ត្រនៅក្បែរកន្លែងធ្លាយប្រេង។ ក្នុងនោះរួមមាន (i)អ្នកទាមទារប្រាក់សំណងនៅក្នុង Florida Keys និង ប្រជុំកោះ Florida ក៏ដោយ(ii) អ្នកទាមទារសំនងនៅតាមបណ្តោយឆ្នេរ Texas និង (iii) អ្នកទាមទារប្រាក់សំណងនៅក្នុងទីតាំងភូមិសាស្ត្រឆ្ងាយពីឈូងសមុទ្រម៉ិកស៊ិក Mexico រួមមាន Baton Rouge រដ្ឋ Louisiana។  ដូចដែលបានកត់សំគាល់ក្នុងវិធីសាស្ត្រចុងក្រោយរបស់ស្ថាប័ន GCCF ទំនាក់ទំនងទីតាំងភូមិសាស្ត្ររបស់អ្នកទាមទារប្រាក់សំណងចំពោះការធ្លាយប្រេង និងស្ថានភាពអាជីវកម្មរបស់អ្នកទាមទារប្រាក់សំណងគឺមានការពាក់ព័ន្ធខ្ពស់ទៅនឹងការម្រេច ទាំងសហេតុកម្មផង និងការទូទាត់សងសំណងផង។ វិធីសាស្ត្រចុងក្រោយ 2។

គឺថាការខាតបង់ត្រូវតែកើតឡើងដោយសារគ្រោះថ្នាក់ដល់ទ្រព្យសម្បត្តិ ឬធនធានធម្មជាតិដើម្បីអោយមានលក្ខណៈទទួលបានការទូទាត់ដោយយោងទៅតាមច្បាប់ OPA  វាមានការលំបាកក្នុងគិតមើល ដែលអ្នកទាមទារសំណងមានទីតាំងភូមិសាស្ត្រឆ្ងាយពីការធ្លាយប្រេងអាចអនុលោមទៅតាមតម្រូវការសហេតុកម្មរបស់ច្បាប់ OPA

ព្រោះអ្នកទាមទារប្រាក់សំណងពុំអាចមានការខាតបង់ដោយសារគ្រោះថ្នាក់ដោយផ្ទាល់ចំពោះទ្រព្យសម្បត្តិ ឬធនធានធម្មជាតិដែលបណ្តាលមកពីការធ្លាយប្រេង។ ប៉ុន្តែក្នុងចំនួនអប្បបរមាស្ថាប័ន GCCF

ត្រូវតែវាយតម្លៃថាតើការការទូទាត់នោះបានស្របតាមតម្រូវការសហេតុកម្មរបស់ច្បាប់ OPA ឬអត់។

តុលាការឧទ្ធរណ៍សហរដ្ឋអាមេរិកជុំទីប្រាំបួនបានបកស្រាយបញ្ហាយ៉ាងច្បាស់នៅក្នុងក្តីវិវាទដែលកើតឡើងពីការធ្លាយប្រេង*Exxon Valdez*។ នៅក្នុង*Adkins v.*

*មូលនិធិទំនួលខុសត្រូវបំពង់ប្រេង Alaska*

101 F.3d 86 (ជុំទី 9 ឆ្នាំ 1996)

តុលាការជុំទីប្រាំបួនបានទទួលស្គាល់ការបដិសេធពាក្យបណ្តឹងទាមទារប្រាក់សំណងជួសជុលនាវា និងក្រុមហ៊ុននេសាទកំសាន្ត ដោយអនុលោមតាមក្រមច្បាប់ផ្តល់សិទ្ធិអនុញ្ញាតិបំពង់ប្រេង Alaska ("TAPAA") ដែលមានអត្ថន័យ ប្រហាក់ប្រហែលគ្នា

ប៉ុន្តែតម្រូវការសហេតុកម្មមិនសូវមានភាពជាក់លាក់ទេ ព្រោះអ្នកទាមទារប្រាក់សំណាង "មានទីតាំងនៅក្រៅតំបន់កំណត់ភូមិសាស្ត្រនៃការធ្លាយប្រេង"

ដូច្នេះពុំមានលក្ខណៈស្របទៅតាមតម្រូវការសហេតុកម្មទេ។ *Id.* នៅ 89 ដូចគ្នានេះដែរនៅក្នុង *ស្តីពី Exxon Valdez*, 270 F.3d 1215 (ជុំទី 9

តុលាការជុំទីប្រាំបួនបានទទួលស្គាល់ការការចេញសាលក្រមសង្ខេបសម្រាប់អ្នកទាមទារប្រាក់សំណាងនៅក្រៅនៃតំបន់នេសាទក្បែរនោះ បានសេចក្តីថា

"តម្រូវការឧបសគ្គបណ្តាលអោយកើតមាននោះនៅឆ្ងាយ

ហើយពាក្យបណ្តឹងទាមទារសំណងមិនមានភាពច្បាស់លាស់។" *Id.* នៅ 1253

(បានសង្កត់ធ្ងន់បន្ថែមទៀត)។

ច្បាប់ OPA

មិនបានពង្រីកវិសាលភាពអ្នកទាមទារប្រាក់សំណងមានទីតាំងភូមិសាស្ត្រឆ្ងាយ

ត្រូវបានទទួលស្គាល់ដោយអ្នកឯកទេសផ្នែកច្បាប់ផ្ទាល់របស់ស្ថាប័ន GCCF សាស្ត្រាចារ្យ

John Goldberg នៃសាលាច្បាប់ Harvard ដែលជាអ្នកពន្យល់ថានៅក្នុងរបាយការណ៍[17]

ដាក់ជូនទៅស្ថាប័ន GCCF:

> ភាសាលក្ខន្តិកៈរបស់ច្បាប់ [OPA] ត្រូវបានយល់យ៉ាងច្បាស់ដើម្បីអនុញ្ញាតអោយស្តារឡើងវិញតែចំពោះអ្នកទាមទារសំណងទៅលើការការខាតបង់សេដ្ឋកិច្ចទាំងនោះ ដែលមានភស្តុតាងបង្ហាញថា ពួកគេបានទទួលរងនូវការខាតបង់សេដ្ឋកិច្ចមែន។ ពីព្រោះការធ្លាយប្រេងបានធ្វើអោយខូចខាត បានបំផ្លាញ ឬមិនដូច្នោះការធ្លាយប្រេងមិនអាចអោយពួកគេអាចទាញយក ទ្រព្យសម្បត្តិ ឬធនធានដែលពួគគេមានសិទ្ធិប្រើប្រាស់ក្នុងអាជីវកម្ម. . . . ផ្ទុយមកវិញ អ្នកប្រតិបត្តិការណ៍នៃតំបន់លំហែរកាយតាមឆ្នេរសមុទ្រនៅក្នុងតំបន់ មិនបានទទួលរងដោយសារការធ្លាយប្រេងទេ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយការទទួលរងការខាតបង់សេដ្ឋកិច្ចទាំងនោះដោយសារតែការថយចុះនៃទេសចរណ៍និយាយជារួម ដែលបណ្តាលមកពីការធ្លាយប្រេង គឺក្នុងចំណោមអ្នកទាំងនោះ គឺជាអ្នកដែលមិនមានសិទ្ធិទទួលបានការស្តារឡើងវិញដោយយោងតាមច្បាប់ OPA។″ សេចក្តីជូនដំណឹងរបស់ Goldberg 3.

> ‶. . . ពាក្យ ‵ដោយសារតែ′ ក្នុងផ្នែក 2702(b)(2)(E) ស្តីពីតម្រូវការសហេតុកម្មស្រទាប់ទីពីរនៅផ្នែកខាងលើតម្រូវការ ‵បណ្តាលមកពី′ ត្រូវបានលើកមកនិយាយក្នុងផ្នែកនេះ 2702(a).″ *Id.* at 17.

> ‶ក្នុងគោលបំណងអានច្បាប់ OPA នៅកម្រិតណាមួយ និង ការខាតបង់ប្រាក់ចំណេញណាមួយ និងការថយចុះសមត្ថភាពរកប្រាក់ចំណូល . . . នឹងមិនអនុញ្ញាតិអោយប្រើពាក្យ ‵ដោយសារតែ ′ –

ចាត់ទុកជាផ្នែកសំណល់។" *Id.* នៅ
18.

"ដូច្នេះ តាមពិតទៅ
នៅពេលប្រឈមមុខជាមួយនឹងប្រការបណ្ដោះអាសន្នក្នុងការទទួលខុសត្រូវលើ
លក្ខន្តិក: ដែលប្រើភាពខុសគ្នារបស់ឃ្លា 'បណ្ដាលមកពី'
*ដូចជាតម្រូវការសហេតុកម្ម* តែមួយគត់ តុលាការបានថែង

17 John C. P. Goldberg
"ភាពទទួលខុសត្រូវសម្រាប់ការខាតបង់សេដ្ឋកិច្ចភ្ជាប់ជាមួយនឹងការធ្លាយប្រេងនៅតំបន់ទឹក
ជ្រៅ Deepwater Horizon" ថ្ងៃទី 22 ខែវិច្ឆិកា ឆ្នាំ 2010*អាចចូលបានតាមរយៈគេហទំព័រ*
http://www.gulfcoastclaimsfacility.com/press (ចូលទស្សនាចុងក្រោយបំផុត នៅថ្ងៃទី 6
ខែឧសភា ឆ្នាំ2011)។

ស្វែងយល់ឃ្លានោះទាំងតម្រូវការសហេតុកម្មជាក់ស្តែង និងការកំណត់មូលហេតុប្រហាក់ប្រហែល – ក្រោយមក ក្រៅពីការទទួលខុសត្រូវចំពោះប្រភេទណាមួយនៃវិបាក ‘ឆ្ងាយដាច់ស្រយាល’។*Id.* នៅ 20 (សង្កត់ធ្ងន់លើប្រភពដើម)។

2. <u>អ្នកទាមទារប្រាក់សំណងនៅឆ្ងាយខាងសេដ្ឋកិច្ច</u>

ការប្រើប្រាស់ការសន្មតរកមូលហេតុរបស់ស្ថាប័ន GCCF បាននាំអោយឈានទៅដល់ការទូទាត់ចំណាយរបស់ស្ថាប័ន GCCF ទៅអោយអ្នកទាមទារប្រាក់សំណងអាជីវកម្មដែលមិនបានទទួលរងការខាតបង់ដោយផ្ទាល់ដែលបណ្តាលមកពីការគ្រោះមហន្តរាយដល់ទ្រព្យសម្បត្តិ ឬធនធានធម្មជាតិដោយសាការធ្លាយប្រេង។ ក្នុងនោះរួមមាន រោងច្រក និងភ្នាក់ងារលក់រាយសម្ភារៈសំណង់ អ្នកម៉ៅការសំណង់ អ្នកមុជទឹក ជាងភ្លើង ជាងទឹក ជាងសោ ភ្នាក់ងារផ្សាយពាណិជ្ជកម្ម ស្ថាបត្យករ អ្នករចនាម៉ូត អ្នកលក់គ្រឿងអគ្គិសនី សេវាកម្ម និងលក់រថយន្ត សាខាចែកចាយភេសជ្ជៈ និងអាហារ និងបារ និងសណ្ឋាគារ និងកម្មករនៅ New Orleans (ទីក្រុង ដែលទទួលរងផលប៉ះពាល់ក្រោយព្រឹត្តិការណ៍ធ្លាយប្រេង) និងផ្សេងទៀត។

ទំនាក់ទំនងផ្សេងទៀតរវាងអ្នកទាមទារប្រាក់សំណង និងទ្រព្យសម្បត្តិ

ឬធានធានធម្មជាតិដែលរងគ្រោះមហន្តរាយកាន់តែប្រយោលប៉ុន្មាន

គឺថាសមត្ថភាពអ្នកទាមទារប្រាក់សំណងកាន់តែសិទ្ធិមានទទួលបានការទូទាត់ប្រាក់សំណង

ដោយយោងតាមច្បាប់ OPA។ ត្រូវតែមាន

"ទំនាក់ទំនងដោយផ្ទាល់ខ្លះៗរវាងគ្រោះមហន្តរាយដែលសមនឹងទាមទារ

និងការរងរបួសដែលបានអះអាងថាមាន។" *Hemi Grp. LLC v. ទីក្រុង New York* _

______________________________សហរដ្ឋអាមេរិក__, 130 S. Ct. 983, 989 (2010)

(ការដកស្រង់ពីច្បាប់ដើមមានខ្វះចន្លោះ)។ ការខាតបង់ដោយប្រយោល

និងការខាតបង់ដែលកើតឡើងគ្មានការទូទាត់សងទេ ទំនាក់ទំនងគឺ

"'ឆ្ងាយដាច់ស្រយាលណាស់' 'ថៃដន្យទាំងស្រុង' ឬ 'ប្រយោ[ល]' មិនគ្រប់គ្រាន់ទេ។" *Id.*

ក្រៅពីនេះ

ទ្រឹស្តីនៃពាក្យមូលហេតុត្រឹមត្រូវបានលុបចោលការស្តាឡើងវិញដោយអ្នកទាមទារប្រាក់សំណា

ងដែលបានខាតបង់ដោយផ្ទាល់នៅក្នុងខ្សែចង្វាក់មូលហេតុនេះ។ "និន្នាការ

ទូទៅរបស់ច្បាប់ យ៉ាងហោចណាស់ក៏មានការយកចិត្តទុកដាក់ទៅលើការខូចខាតដែរ

គឺមិនអាចផុតពីជំហានដំបូងនេះទេ។'" *Holmes v. Sec. និតិក្រុមរបស់អ្នកវិនិយោគ Corp.*, 503

U.S. 258, 271-72 (1992) (ដកស្រង់ពី *Assoc. Gen. ក្រុមហ៊ុនអ្នកទទួលម៉ៅការ Cal., Inc. v. Cal. ក្រុមប្រឹក្សាជាងឈើប្រចាំរដ្ឋ*459 U.S. 519, 534 (1983), ដកស្រង់ *S. Pac. Co. v. ក្រុមហ៊ុន Darnell- Taenzer Lumber*, 245 U.S. 531, 533 (1918)); *សហភាពកម្មករអាជីវកម្ម និងសហព័ន្ធអាហារមូលនិធិសុខមាលភាព និងសុខភាព Emp'rs។ ក្រុមហ៊ុន Philip Morris*, 223 F.3d 1271, 1273 (11th Cir. 2000) (ប្រការច្បាប់

ច្បាប់ "បញ្ឈប់ជំហានដំបូងនៅក្នុងខ្សែចង្វាក់សហេតុកម្ម ហើយសំលឹងមើលទៅតែបុគ្គលណាដែលប្រហែលជាមានមូលហេតុរងរបួសពិតប្រាកដ។

ម្តងទៀត សេក្តីសម្រេចរបស់តុលាការជុំទីប្រាំបួនគឺការណែនាំ ។ ឧទាហរណ៍ នៅ*ឯការសម្រេចរបស់តុលាការជុំទីប្រាំបួន*បានគាំទ្រភស្តុតាង ភោជនីដ្ឋានដែលបានកំពុងដាក់បណ្តឹងទាមទារសំណងថា គេបានខាតបង់អាជីកម្ម នៅពេលអតិថិជនរបស់ខ្លួនដែលជាអ្នកនេសាទ មិនបានមកនេសាទត្រីតទៅទៀតដោយសារតែការបិទដែននេសាទ គឺមានការលំបាកក្នុងស្តារឡើងវិញ។ *Adkins*, 101 F.3d នៅ 88។ ក្រៅពីនេះ នៅ *Benefiel v. Exxon* , 959 F.2d 805 (តុលាការជុំទី 9 1992) តុលាការបានរំសាយសកម្មភាពដែលបានអះអាងដោយអ្នកប្រើប្រាស់ជាពលរដ្ឋ California ដែលស្របតាម*Exxon Valdez* ការធ្លាយប្រេងបានធ្វើអោយតម្លៃឧស្ម័នកើនឡើង ដែលថ្លែងក្នុង "សមាជ TAPAA ដែលកំពុងអនុម័តមិនមានបំណងទុកជាមោឃះនូវគោលការណ៍ទាំងអស់នៃភាពប្រហាក់ប្រហែលនៃមូលហេតុដែលបណ្តាលអោយមាននោះទេ" *Id*។ 807។

C. ស្ថាប័ន GCCF ត្រូវតែវាយតម្លៃសមស្របមួយ
<u>ប្រវត្តិអ្នកទាមទារប្រាក់សំណង' កិច្ចខំប្រឹងប្រែងស្តារសេដ្ឋកិច្ច</u>

យោងតាម ច្បាប់នៃការខូចខាតដែលបានបង្កើតឡើង

ដើមក្តីគ្រាន់តែមានសិទ្ធិគ្រប់គ្រាន់ទៅលើការខូចខាត

ដែលបានបង្ហាញអោយឃើញពីភាពស្របច្បាប់ណាមួយនោះ។

ការខូចខាតដោយសារការព្យាករណ៍នឹងមិន អាចទទួលយកទេ។ *សូមមើលឧទាហរណ៍ MKR*

*Svcs., LLC. v. Dean Hart Constr., L.L.C.*, 16 So. 3d 562 (La. Ct. App. 2009); *Holt v. Bethany*

*Land Co.*, 843 So. 2d 606 (La. Ct. App. 2003); *Miller Indus. v. Caterpillar Tractor Co.*, 733 F.2d

813 (11th Cir. 1984) (អនុវត្តច្បាប់ទូទៅស្តីពីសមុទ្រសហព័ន្ធ) *Water Craft Mgmt., L.L.C. v.*

*Mercury Marine*, 638 F. Supp. 2d 619 (M.D. La. 2009) (ការអនុវត្តច្បាប់រដ្ឋ Louisiana);

*ស្តីពីក្រុមហ៊ុន Discount Cigarette, Cigars ។ល។*, 399 B.R. 605 (M.D. La. 2009).

ច្បាប់នេះក៏បានលើកឡើងនៅក្នុងវិធីសាស្រ្តចុងក្រោយរបស់ស្ថាប័ន GCCF

ក្នុងលក្ខខណ្ឌនៃការទូទាត់ប្រាក់សំណងនឹងឈរលើ

"ការខាតបង់ដែលមានចុះក្នុងឯកសារជាក់ស្តែង

ហើយទទួលរងដោយអ្នកទាមទារប្រាក់សំណងតាំងពីពេល

ដែលការខាតបង់ចាប់ផ្តើមចាប់តាំងពីមានការផ្លាយប្រេងនៅថ្ងៃទី[20] ខែមេសា ឆ្នាំ 2010។˝

វិធីសាស្ត្រចុងក្រោយ 3 (ខ្វះចន្លោះក្នុងច្បាប់ដើម)។

ក្នុងករណីខ្លះ ស្ថាប័ន GCCF

មិនបានធ្វើតាមគោលការណ៍មូលដ្ឋាននៃការគណនាទៅលើការខូចខាតទេ។ ជាបញ្ហាដំបូង

នៅពេលដែលស្ថាប័ន GCCF មិនបានចាប់អារម្មណ៍ពីនិន្នាការនៃផលទុនធ្លាក់ចុះទេ។

ឧទាហរណ៍

អ្នកទាមទារប្រាក់សំណងមួយចំនួនបានបង្ហាញអោយឃើញការធ្លាក់ចុះផលទុនតាំងពីមុនមា

នការផ្លាយប្រេងក្នុង

កំឡុងខែមករា-មេសា ឆ្នាំ2010 បើប្រៀបធៀបទៅនឹងខែមករា-មេសា ឆ្នាំ2009 ឬសម្រាប់ឆ្នាំ2009 ប្រៀបទៅនឹងឆ្នាំ2008។ តែ ថ្វីបើមានលក្ខណៈអវជ្ជមាននេះក៏ដោយ ក៏ស្ថាប័ន GCCF បានសម្មតថា ប្រសិនបើគ្មាននៃការធ្លាយប្រេងទេ នោះអជីវកម្មនៅកំឡុងខែឧសភា-ធ្នូ ឆ្នាំ2010 នឹងមានការប្រសើរឡើងខ្លាំង។

ក្រៅពីនេះ សម្រាប់ពាក្យបណ្តឹងមួយចំនួន និងក្នុងករណីមួយចំនួន ស្ថាប័ន GCCF បានយល់ព្រមសន្មតថាការកើនឡើងនូវផលទុននៃឆ្នាំ 2009 ច្រើនជាងឆ្នាំ 2008 នឹងស្មើពីរដងនៅឆ្នាំ 2010 ប៉ុន្តែសម្រាប់ការធ្លាយប្រេង។ ការសម្រេចថាតើកំណើនផលទុនដ៏ធំក្នុងឆ្នាំ 2009 នេះនឹងកើតមានឡើងវិញដោយខ្លួនឯងនៅឆ្នាំ2010 គឺជាការមួយដែលមិនអាចទទួលយកបានក្នុងការសន្មតមួយ។ ក្រៅពីនេះ ស្ថានភាពជាក់លាក់នៃពាក្យបណ្តឹងទាមទារប្រាក់សំណងនីមួយៗត្រូវតែត្រូវបានវាយតម្លៃដើម្បីឆ្លើយសំនួរនេះ។

D. ប្រាក់ចំណូលដែលរកបានក្នុងកំឡុងកម្មវិធីផ្តល់ឱកាសដល់នាវាកៀប្រេង <u>ត្រូវតែទូទាត់សងសំនងដោយផ្អែកលើសេក្តីសម្រេចស្តីពីការខូចខាត</u>

មកដល់សព្វថ្ងៃនេះ ស្ថាប័ន GCCF

មិនបានទូទាត់សងសំណងលើការទូទាត់ចំនួនប្រាក់ដែលរកបានដោយអ្នកទាមទារសំណង

សម្រាប់ការខូចខាតរបស់ខ្លួនពីការចូលរួមក្នុងយុទ្ធនាការ

ឆ្លើយតបតាមរយៈកម្មវិធីផ្តល់ឱកាសដល់នាវាកៀ ប្រេង("VoO")។ ច្បាប់ OPA

ស្មើអោយកម្មវិធីផ្តល់ឱកាសដល់នាវាកៀប្រេង VoO

ដែលរកចំណូលបានធ្វើការទូទាត់សងសំណងចំពោះការទូទាត់សំណងលើការខូចខាតនៃស្ថាប័

ន GCCF។

ផ្នែក 2702(b)(2)(E) នៃច្បាប់ OPA

ផ្តល់ជូនការស្តារឡើងវិញនូវប្រាក់ចំណូលដែលបានខាតបង់

និងប្រាក់ចំណេញដែលខាតបង់នៅក្នុងស្ថានភាពណាមួយ។

នៅពេលបទបញ្ញារនៃការិយាល័យឆ្នាំឆ្នេរសមុទ្រ

ដែលគ្រប់គ្រងពាក្យបណ្តឹងទាមទារប្រាក់ចំណូលបាត់បង់

ដែលបានផ្តើមកម្មលនិធិទំនុកចិត្តលើការទទួលខុសត្រូវចំពោះការធ្លាយប្រេងបានធ្វើអោយច្បា

ស់លាស់ហើយ ការទូទាត់ទៅលើការខូចខាតត្រូវបានកែតម្រូវក្នុងការគណនាសម្រាប់

"[ប្រាក់]ចំណូលទាំងអស់ដែលបានមកពីឧបទ្ទវហេតុ" និង

"[ប្រាក់]ចំណូលទាំងអស់ដែលមកពីការងារ ឬអាជីកម្មផ្សេងទៀត។" 33 C.F.R. § 136.235(a)-

(b). ប្រាក់ចំណូលដែលរកបានដោយការចូលរួមនៅក្នុង

យុទ្ធនាការឆ្លើយតបទៅនឹងកម្មវិធីផ្តល់ឱកាសដល់នាវាកៀប្រេងដាក់បង្កើតអោយមានប្រាក់ចំ

ណូលដែលរកបានពីការធ្លាយប្រេង និងប្រាក់ចំណូល

ដែលរកបានពីការងារផ្សេងទៀត
ដូច្នេះហើយត្រូវតែទូទាត់ចំពោះសេចក្តីសម្រេចណាមួយទៅលើការខូចខាតរបស់ស្ថាប័ន GCCF។

ការិយាល័យឆ្នាំឆ្នេរសមុទ្របញ្ជាក់ពីចំនុចនេះនៅក្នុងសំនួរចម្លើយដែលកើតមានជាញឹក

គេហទំព័រ18: ញាប់បានបិទផ្សាយនៅលើគេហទំព័ររបស់ខ្លួន

សំនួរចម្លើយដែលកើតមានជាញឹកញាប់-5:
ប្រសិនបើខ្ញុំធ្វើពាក្យបណ្តឹងទាមទារប្រាក់សំណងសម្រាប់ការខាត
បង់ប្រាក់ចំណូលដែលបណ្តាលមកពីការធ្លាយប្រេង
តើខ្ញុំនឹងទទួលបានប្រាក់ចំណូលខ្លះពីការងារផ្សេងទៀត
រួមមានការងារជាអ្នកចូលរួមក្នុងយុទ្ធនាការឆ្លើយតបទៅនឹងការធ្លា
យប្រេង ឬប្រាក់ចំណូលនិកម្មជន
ដែលត្រូវបានសម្រេចដោយការកំណត់ទៅលើការទូទាត់?

A: បាទ។
នៅពេលសម្រេចការទូទាត់ទៅលើពាក្យបណ្តឹងទាមទារប្រាក់ចំ
ណោញ
ឬប្រាក់ចំណូលរកបានដែលបានខាតបង់ដែលផ្ញើមកដោយបុគ្គល
និងអាជីកម្ម NPFC
នឹងទាមទារអោយអ្នកទាមទារប្រាក់សំណងផ្តល់ព័ត៌មានពីប្រាក់ចំ
ណូលបានមកពីការងារផ្សេងទៀត
រួមមានប្រាក់ចំណូលពាក់ព័ន្ធទៅនឹងការងារ
ឬការលក់ដូរណាមួយដែលគួបផ្សំនឹងការចូលរួមក្នុងយុទ្ធនាការឆ្លើ
យតបទៅនឹងការធ្លាយប្រេង
និងប្រាក់ចំណេញនិកម្មជនដែលទទួលបាន។
ប្រាក់ចំណូលនោះនឹងត្រូវបានសម្រេចដោយការកំណត់នូវការខា
តបង់ពិតប្រាកដដើម្បីធ្វើការទូទាត់សងជាសំណង។

ដូចជាបទបញ្ជារការិយាល័យឆ្នាំឆ្នេរសមុទ្រ និតិក្រមផ្ទាល់ខ្លួនរបស់ស្ថាប័ន GCCF

ក៏បានគណនាបំពេញទៅលើប្រាក់ចំណូលកម្មវិធី ផ្តល់ឱកាសដល់នាវាកៀប្រេង VoO។ ផ្នែកទី

II.C.2 នៃនិតិក្រមសម្រាប់ពាក្យបណ្ដឹងទាមទារប្រាក់សំណងចុងក្រោយ

និងបណ្ដោះអាសន្នតម្រូវអោយអ្នកទាមទារប្រាក់សំណងផ្ញើទៅផ្នែកព័ត៌មាននៃស្ថាប័ន GCCF

អំពី "[ប្រាក់ចំណូល]រកបានដែលទទួលពីការងារ ឬអាជីវកម្មផ្សេងទៀតក្នុងដំណាក់ការ

នៃការខាតបង់

ហើយការចំណាយកើតឡើងពេលមានការបង្កើតអោយប្រាក់ចំណូលផ្សេងទៀត។"

* * *

សរុបមក ក្រុមហ៊ុនប្រេងប៊ីភី BP បានស្នើសុំដោយក្ដីគោរពរាប់អានទៅស្ថាប័ន GCCF បង្កើតអោយមានការផ្លាស់ប្ដូរដែលលើកឡើងនៅខាងលើ ដូច្នេះដើម្បីឆ្លុះអោយឃើញពីវិស័យទេសចរណ៍នៅតំបន់ឈូងសមុទ្ររដ្ឋបច្ចុប្បន្នភាព និងការកែតម្រូវដោះស្រាយដំណើរការពាក្យបណ្ដឹងទាមទារប្រាក់សំណងរបស់ខ្លួនជាមួយនឹងការលក្ខខណ្ឌកំណត់ ដែលដាក់ចេញដោយច្បាប់ OPA។

---

[18] សំនួរចម្លើយដែលកើតមានជាញឹកញាប់របស់អ្នកទាមទារប្រាក់សំណងក្នុងករណីបញ្ហានៅតំបន់ទឹកជ្រៅ Deepwater Horizon របស់មជ្ឈមណ្ឌលមូលនិធិនៃភាពកង្វក់ជាតិ*អាចចូលបានតាមរយៈគេហទំព័រ* http://www.uscg.mil/npfc/Claims/DWH_faqs.asp#GCCF (ចូលទស្សនាចុងក្រោយបំផុតនៅថ្ងៃទី 5 ខែឧសភា ឆ្នាំ2011).